# ជំពូកទី៤

# ស្ថានភាពធនធានបរិស្ថាន

# ដែលមានស្រាប់

Draft

# ជំពូកទី ៤

# ស្ថានភាពធនធានបរិស្ថានដែលមានស្រាប់

## ៤.១ សេចក្តីផ្តើម

ការសិក្សាលើធនធានបរិស្ថានដែលមានស្រាប់ផ្តោតទៅលើធនធានបីសំខាន់ៗ គឺធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ដែលស្ថិតនៅក្បែរ និងក្នុងតំបន់គំរោង។ ធនធានរូបសាស្ត្រ ផ្តោតសំខាន់ទៅលើផ្នែកឋានលេខា ភូគព្ភសាស្ត្រ ជលសាស្ត្រ អាកាសធាតុ និងគុណភាពទឹកលើដី។ ចំណែកធនធានជីវសាស្ត្រ វិញសិក្សា ទៅលើធនធានព្រៃឈើ និងសត្វព្រៃ។ ធនធានចុងក្រោយ ជាធនធានសេដ្ឋកិច្ច-សង្គម ត្រូវបានសិក្សាទៅលើប្រជា- សាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ ការប្រើប្រាស់ដីក្នុងភូមិ ការប្រើប្រាស់ទឹក កិរិតវប្បធម៌របស់ប្រជាជន គ្រោះធម្មជាតិ និងប្រពៃណីវប្បធម៌ ទីសក្ការៈ និងតំបន់ទេសចរណ៍។

ការពិពណ៌នាពីធនធានសំខាន់ៗ ខាងលើនេះ ក្នុងគោលបំណងស្វែងយល់ពីធនធានដែលមានស្រាប់នៅក្បែរ និងនៅក្នុងតំបន់សុំដីសម្បទានរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** (SETHIKULA Co., Ltd) ដែលអាចរងការប៉ះពាល់ ដោយសារតែវត្តមានរបស់គំរោង។ ការប្រមូលព័ត៌មានទៅលើធនធានបរិស្ថាន ដែលមានស្រាប់នេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រប្រមូលទិន្នន័យបែបបឋម និងបន្ទាប់បន្សំ។

## ៤.២ ធនធានរូបសាស្ត្រ

### ៤.២.១ ឋានលេខា

#### ក. សណ្ឋានដី

#### ក.១ រយៈកំពស់

យោងតាមទិន្នន័យនៃ រយៈកំពស់របស់ផែនទីមាត្រដ្ឋាន ១: ១០០.០០០ របស់ JICA ឆ្នាំ២០០២ បានបញ្ជាក់ថានៅក្នុងតំបន់គំរោងនេះ ជាតំបន់ខ្ពង់រាបដែលមានរយៈកំពស់ជាមធ្យម ៥៣៧.១១ ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ។ ការប្រែប្រួលនៃរយៈកំពស់នៅក្នុងតំបន់គំរោង គឺមានស្ថានភាពទាប នៅភាគខាងជើងនៃគំរោង (តំបន់ជ្រលងអូររវេត អូររកាំង អូរអ៊ីល និងអូរដាក់រកាន) ដែលមានរយៈកំពស់អប្បបរមាត្រឹម ៣៦០ ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ និងមានសភាពខ្ពស់ខ្លាំងនៅតំបន់ភាគខាងត្បូងតាមព្រំប្រទល់គំរោង ដែលមានរយៈកំពស់អតិបរមាដល់ ៧០០ ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ (ឧបសម្ព័ន្ធ ១-៤)។



Draft

## ក.២ ចំណាត់ថ្នាក់ទីជំរាល

យោងតាមទិន្នន័យស្តីពីរយៈកំពស់នៅក្នុងផែនទីមាត្រដ្ឋាន ១ : ១០០.០០០ របស់ JICA ឆ្នាំ ២០០២ បានបញ្ជាក់ថា តំបន់ដែលមានទីជំរាលខ្លាំងភាគច្រើន ស្ថិតនៅភាគខាងជើងក្នុងតំបន់គំរោង។ កំរិតជំរាល មានការប្រែប្រួលពី ០-៤៥ ដឺក្រេ ដោយមានទីជំរាលជាមធ្យមគឺ ៥.៣៤ ដឺក្រេ។ ទីជំរាល ត្រូវបានបែងចែកជា ០៤ ចំណាត់ថ្នាក់ដូចខាងក្រោម :

- **កំរិតជំរាលចន្លោះពី ០-៥ ដឺក្រេ** : ជាតំបន់ជំរាលខ្សោយ។ តំបន់នេះត្រូវការអភិរក្សប្រភពទឹក និងដីស្រទាប់លើ ដោយផ្អែកទៅលើលក្ខខណ្ឌក្នុងតំបន់។ ដើម្បីអភិរក្សប្រភពទឹក និងដីស្រទាប់លើ តំបន់នេះ ត្រូវការដាំដំណាំកសិកម្មផ្សេងៗ និងរក្សាព្រៃឈើ។ កំរិតជំរាលនេះ មានទំហំផ្ទៃដី ២.២០៤ ហិកតា ស្មើនឹង ៥១.៥៩% នៃផ្ទៃដីគំរោងសរុប ៤.២៧៣ ហិកតា ដោយស្ថិតនៅក្នុងអនុតំបន់ទី១ ចំនួន ៣៦៨ ហិកតា អនុតំបន់ទី២ ចំនួន ៣៣២ ហិកតា អនុតំបន់ទី៣ ចំនួន ៣៤៤ ហិកតា អនុតំបន់ទី៤ ចំនួន ៦៣០ ហិកតា និងអនុតំបន់ទី៥ ចំនួន ៥៣០ ហិកតា។
- **កំរិតជំរាលចន្លោះពី ៥-២០ ដឺក្រេ** : ជាតំបន់ជំរាលមធ្យម។ ការប្រើប្រាស់ដីនៅតំបន់នេះ តំរូវឱ្យមានការអភិរក្សប្រភពទឹក និងស្រទាប់ដីលើ ដោយរក្សានូវគំរបព្រៃតាមប្រភពសំខាន់ៗ។ ដីនៅតំបន់នេះ អាចប្រើសំរាប់ធ្វើជាព្រៃ ពាណិជ្ជកម្ម ការចិញ្ចឹមសត្វ និងការដាំរួមផ្សំគ្នា រវាងដំណាំកសិកម្ម និងឈើ ដោយមានវិធានការអភិរក្សត្រឹមត្រូវ។ កំរិតជំរាលនេះ មានទំហំផ្ទៃដី ១.៨៨០ ហិកតា ស្មើនឹង ៤៤% នៃផ្ទៃដីសរុបរបស់ គំរោង ដោយស្ថិតនៅក្នុងអនុតំបន់ទី១ ចំនួន ១០២ ហិកតា អនុតំបន់ទី២ ចំនួន ១៦៨ ហិកតា អនុតំបន់ទី៣ ចំនួន ១៥៦ ហិកតា អនុតំបន់ទី៤ ចំនួន ៧០២ហិកតា និងអនុតំបន់ទី៥ ចំនួន ៧៥២ ហិកតា។
- **កំរិតជំរាលចន្លោះពី ២០-៣០ ដឺក្រេ** : ជាតំបន់ជំរាលចោត។ ទំរង់ដីនេះជាទូទៅមានកំរិតជ្រាបទឹកទាប និងអាចមានសំណឹកដីកើតឡើង។ ការប្រើប្រាស់ដីនៅក្នុងតំបន់នេះតំរូវឱ្យមានការរក្សាព្រៃឈើ។ ដីនៅតំបន់នេះអាចប្រើ សំរាប់ធ្វើការចិញ្ចឹមសត្វ និងការដាំរួមផ្សំគ្នារវាងដំណាំកសិកម្ម និងឈើ ដោយមានវិធានការអភិរក្សតឹងរឹង។ កំរិតជំរាល នេះ មានទំហំផ្ទៃដី ១៧៥ ហិកតា ស្មើនឹង ៤.១០% នៃផ្ទៃដីគំរោងសរុប ដោយស្ថិតនៅក្នុងអនុតំបន់ទី១ ចំនួន ០៦ ហិកតា អនុតំបន់ទី២ ចំនួន ០១ ហិកតា អនុតំបន់ទី៣ ចំនួន ០៣ហិកតា អនុតំបន់ទី៤ ចំនួន ៨៣ហិកតា និងអនុតំបន់ទី៥ ចំនួន ៨៣ ហិកតា។
- **កំរិតជំរាលចាប់ពី ៣០ ដឺក្រេ ឡើងទៅ** : ជាតំបន់ជំរាលចោតខ្លាំង។ នៅតំបន់នេះ ដីមានលក្ខណៈហាប់ណែន និងជាតំបន់ក្បាលទឹក។ តំបន់នេះមានសារៈសំខាន់សំរាប់ការគ្រប់គ្រងប្រភពទឹក និងស្រទាប់ដីលើ។ ការប្រើប្រាស់ដីនៅ ក្នុងតំបន់នេះ តំរូវឱ្យមានជាក្រិត្យក្រម និងគួរតែជាតំបន់ដែលមានគំរបព្រៃឈើអចិន្ត្រៃយ៍។ កំរិត

Draft

ជំរាលនេះ មានទំហំផ្ទៃដី ១៣ ហិកតា ស្មើនឹង ០,៣១% នៃផ្ទៃដីគំរោងសរុប ដោយស្ថិតនៅក្នុងអនុតំបន់ទី១ ចំនួន ០១ ហិកតា អនុតំបន់ទី៤ ចំនួន ០៦ហិកតា និងអនុតំបន់ទី៥ ចំនួន ០៦ ហិកតា (ឧបសម្ព័ន្ធ ១-៥)។

## ខ. ប្រភេទដី

យោងតាមឯកសារផែនការមេរបស់គំរោង និងផែនទីប្រភេទដីរបស់ Charles D. Crocker (Charles D. Crocker Soil Classification) នៅឆ្នាំ ១៩៦២ ដែលបានគូសក្នុងមាត្រដ្ឋាន ១:១០០.០០០ បានបង្ហាញអោយឃើញច្បាស់ថា នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន SETHIKULA Co., Ltd មានប្រភេទដីសំខាន់ៗ ចំនួន ០៣ ប្រភេទ ដូចខាងក្រោម :

- <u>ប្រភេទដី **Basic Lithosols**</u> : មានផ្ទៃដីចំនួន ២២៩៧ ហិកតា ស្មើនឹង ៥២,៨២% នៃផ្ទៃដីសរុប ដោយគ្របដណ្តប់លើដីសម្បទានប៉ែកខាងជើង និងខាងត្បូង។ ស្រទាប់ដីកសិកម្មមានជំរៅពី ១០-២០ សង់ទីម៉ែត្រ និង pH= ៦,៥-៨។
- <u>ប្រភេទដី **Regurs**</u>: មានផ្ទៃដីចំនួន ២០០៨ហិកតា ស្មើនឹង ៤៦,៩៩% នៃផ្ទៃដីគំរោងសរុប ដោយគ្របដណ្តប់លើ ដីសម្បទានភាគកណ្តាលមួយចំណែកធំ ហើយមួយចំណែកតូច មាននៅភាគឥសាន និងភាគពាយ័ព្យ។
- <u>ប្រភេទដី **Latosols**</u> : មានផ្ទៃដីចំនួន ៨ហិកតា ស្មើនឹង ០,១៨% នៃផ្ទៃដីគំរោងសរុប ដោយគ្របដណ្តប់លើដីសម្បទានភាគខាងលិច។ ដីក្រហមបាសាល់ Latosols ជាប្រភេទដីឥដ្ឋទៅ ដីឥដ្ឋ-ល្បាប់ដែមានជីជាតិល្អ។ ស្រទាប់ដីកសិកម្ម មានជំរៅពី ១០-២០សង់ទីម៉ែត្រ និង pH = ៥,៥-៦,៨។ ដីនេះ ជាដីត្រូវការហ្វូស្វាតច្រើន ហើយត្រូវនឹងដំណាំកៅស៊ូ ស្រូវភ្នំ ចេក ពោត សណ្តែក ដំណាំយកផ្លែ តែ កាហ្វេ និងព្រៃចំរុះ ប៉ុន្តែត្រូវមានវិធានការការពារការហូរច្រោះ និងភ្លើងឆេះព្រៃ (ឧបសម្ព័ន្ធ : ១-៦)។

## ៤.២.២ ភូគព្ភសាស្ត្រ

ការសិក្សានូវភូគព្ភសាស្ត្រ អាចឱ្យយើងដឹងបាននូវអាយុដីក្នុងតំបន់ និងបែបផែននៃការករកើតនៅក្នុងតំបន់មួយបាន។ លើសពីនេះទៅទៀត វាក៏អាចចង្អុលបង្ហាញនូវសកម្មភាពនានារបស់តំបន់ផងដែរ ដូចជាពំនើងផ្នត់ បន្ទុះភ្នំភ្លើង និងការករកើតរ៉ែជាដើម។ ដូចគ្នានេះដែរ ចំពោះការសិក្សានូវចំនុចនេះ វាក៏អាចផ្តល់នូវការយល់ដឹងពីលក្ខណៈសម័យកាលនៃកំណរកំណើតដីនៅក្នុងតំបន់គំរោងផងដែរ។ ចំពោះនៅក្នុងតំបន់គំរោងដីសម្បទានរបស់ក្រុមហ៊ុន SETHIKULA Co., Ltd បើតាមឯកសាររបស់នាយកដ្ឋានភូមិសាស្ត្រជាតិឆ្នាំ ២០០៥ បានបង្ហាញថា ដីត្រូវបានកើតឡើងនៅក្នុងសម័យកាល ដីស័កទី ៤ (២ លានឆ្នាំ រហូតមកដល់ពេលបច្ចុប្បន្ន)។ ដីដែលកើតឡើងនៅក្នុងសម័យកាលនេះ គឺគ្របដណ្តប់លើផ្ទៃដី គំរោងទាំងមូល។ ជាទូទៅផ្ទៃដីទាំងមូលមានសភាពស្ងប់ និងជាសម័យកំទេចកំនរ។ នៅប្រទេសកម្ពុជា ប្រព័ន្ធផ្លូវទឹក បាននាំល្បាប់មកចាក់បំពេញតំបន់ទំនាប ពិសេសប្រព័ន្ធទន្លេមេគង្គ។ ស្របពេលជាមួយគ្នានោះ មានចលនា

រុញឡើងយ៉ាង យឺតៗ ពីក្នុងផែនដី ហើយទឹកសមុទ្រក៏ថយបន្តិចម្តងៗបណ្តាលឱ្យលេចឡើងនូវល្បាប់ចាស់ ក្បែរភ្នំដងរែក តាមជួរភ្នំ ក្រវ៉ាញ និងល្បាប់ថ្មី ក្បែរបឹងទន្លេសាប ។ ល្បាបចាស់ និងថ្មីនេះ បង្កើតបានជាតំបន់ខ្ពង់រាប និង ទំនាបកណ្តាលសព្វថ្ងៃ ( ឧបសម្ព័ន្ធ : ១-៧) ។

### ៤.២.៣ ជលសាស្ត្រ

#### ក. ស្ថានភាពផ្លូវទឹកលើដី

ប្រព័ន្ធផ្លូវទឹកដែលស្ថិតនៅក្នុងតំបន់គំរោងរួមមាន :

- **អូររេត** : ជាអូរដែលមានមួយភាគនៅជាប់នឹងព្រំប្រទល់ដីសម្បទាន និងមួយភាគទៀតស្ថិតនៅក្នុងដីសម្បទាន ហើយមានទឹកពេញមួយឆ្នាំ ដោយលាតសន្ធឹងពីទិសខាងជើងទៅទិសខាងត្បូង។ អូរនេះ ស្ថិតក្នុងដីសម្បទានមានប្រវែងប្រមាណ ៦២៧០ ម៉ែត្រ ដោយមាន អូររកាំង អូរអ៊ីល និងអូរដាក់រកាន ជាដៃរបស់វា។
- **អូររណារ** : ជាអូរ ដែលមានសទឹកពេញមួយឆ្នាំ។ អូរនេះមានទីតាំងស្ថិតនៅភាគឥសាននៃដីសម្បទានដោយមានប្រវែងប្រមាណជា ១៩៣៨ ម៉ែត្រ ស្មើនឹង ៧,៣៩% នៃប្រព័ន្ធផ្លូវទឹកក្នុងទីតាំងដីសម្បទានសរុប ។
- **អូរពោត** : ជាអូរ ដែលមានសទឹកពេញមួយឆ្នាំ។ អូរនេះមានទីតាំងស្ថិតនៅភាគឥសាននៃដីសម្បទានដោយមានប្រវែងប្រមាណជា ៤៧៩៥ ម៉ែត្រ ស្មើនឹង ១៨,២៩% នៃប្រព័ន្ធផ្លូវទឹកក្នុងទីតាំងដីសម្បទានសរុប ។
- ចំនែកអូរឆែល និង អូរតែវិច ជាអូរដែលរីងនៅរដូវប្រាំង និងជាដៃរបស់ព្រែកពោធិ៍

( ឧបសម្ព័ន្ធ : ១-៨) ។

#### ខ. គុណភាពទឹកលើដី

ការវិភាគនូវគុណភាពទឹកនៅក្នុងតំបន់គំរោង ត្រូវបានធ្វើឡើង ចំនួន ២ សំណាក :

- **សំណាកទី ១:** ត្រូវបានធ្វើឡើងទៅលើអូរពោត ដែលមានចំនុចនិយាមការ អាប់ស៊ីស ៧៧៣២៩៤ និង អរដោនេ ១៣៨៧៧៤៣ ។
- **សំណាកទី ២:** ត្រូវបានធ្វើឡើងទៅលើអូររេត ដែលមានចំនុចនិយាមការ អាប់ស៊ីស ៧៧០១៨៨ និងអរដោនេ ១៣៨៣៦០៨ ។

ស្របតាមការវិភាគលើសំណាកទឹកទាំង ២ សំណាកខាងលើ យើងបានពិសោធន៍ទៅលើប៉ារ៉ាម៉ែត្រចំនួន ៥ ផ្សេងពីគ្នា ដែលរួមមានដូចជា : pH, BOD, Turbidity, Total Nitrogen និង Total Coliform ដែលប៉ារ៉ាម៉ែត្រទាំងនេះជាប៉ារ៉ាម៉ែត្រដែលសំខាន់សំរាប់ធ្វើការអភិរក្សជីវៈចំរុះ ។ ឆ្លងតាមការវិភាគដោយក្រសួងបរិស្ថានបាន បង្ហាញថាសំណាកទាំងពីរនេះមិនមានប៉ារ៉ាម៉ែត្រណាមួយដែលលើសពីកំរិតបទដ្ឋានក្នុងការអភិរក្សជីវៈចំរុះ ដែលបាន កំណត់ដោយក្រសួង

Draft

បរិស្ថាននោះទេ (ឧបសម្ព័ន្ធ ២)។ តារាងខាងក្រោមនេះ ជាលទ្ធផលនៃការវិភាគទឹកនៅតាមបណ្តាអូរសំខាន់ៗមួយចំនួននៅក្នុងតំបន់គំរោងដីសម្បទាន :

**តារាង ៤.៣ : គុណភាពទឹកនៅតាមប្រព័ន្ធមួយចំនួននៅតំបន់ដីសម្បទាន**

| ល.រ | ប៉ារ៉ាម៉ែត្រ | លទ្ធផល | | ឯកតា | កំរិតបទដ្ឋានរបស់ក្រសួងបរិស្ថាន |
|---|---|---|---|---|---|
| | | ១ | ២ | | |
| ១ | pH | ៦.៦៨ | ៦.៧៤ | - | ៦.៥-៨.៥ [1] |
| ២ | BOD | ១.២ | ១.២៥ | mg/l | ១-១០ [1] |
| ៣ | Turbidity | ៦ | ៤ | NTU | - [2] |
| ៤ | Total Nitrogen | ០.១៨ | ០.១៦ | mg/l | ០.១-០.៦ [1] |
| ៥ | Total Coliform | ១៥០ | ១២០ | Count/100ml | < ៥០០០ [1] |

សំគាល់: [1] បទដ្ឋានសំរាប់គុណភាពទឹកសាធារណៈសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹករបស់ក្រសួងបរិស្ថាន
[2] មិនមានចែងនៅក្នុងបទដ្ឋានសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹករបស់ក្រសួងបរិស្ថានទេ

*ប្រភព: ក្រសួងបរិស្ថាន, ២០០៩*

**គ. គុណភាពទឹកក្រោមដី**

ការវិភាគនូវគុណភាពទឹកនៅក្នុងតំបន់គំរោង ត្រូវបានធ្វើឡើង ចំនួន ១ សំណាក :

- **សំណាកទី ៣ :** ត្រូវបានធ្វើឡើងនៅអណ្តូងទឹកភូមិពូលុ ដែលមានចំនុចនិយាមការ អាប់ស៊ីស ៧៦៤៥០២ និង អរដោនេ ១៣៨៥៩១០។

ស្របតាមការវិភាគលើសំណាកទឹក ខាងលើយើងបានពិសោធន៍ទៅលើប៉ារ៉ាម៉ែត្រចំនួន ៦ ផ្សេង ពីគ្នា ដែលរួមមានដូចជា : pH, Total Coliform, Magnesium, Calcium, Lead និង Arsenic ដែល ប៉ារ៉ាម៉ែត្រទាំងនេះជាប៉ារ៉ាម៉ែត្រដែលសំខាន់សំរាប់ធ្វើការអភិរក្សជីវៈចំរុះ។ ឆ្លងតាមការវិភាគដោយក្រសួងបរិស្ថានបាន បង្ហាញថាសំណាកទាំងពីរនេះមិនមានប៉ារ៉ាម៉ែត្រណាមួយដែលលើសពីកំរិតបទដ្ឋានក្នុងការអភិរក្សជីវៈចំរុះ ដែលបាន កំណត់ដោយក្រសួងបរិស្ថាននោះទេ (ឧបសម្ព័ន្ធ ២)។ តារាងខាងក្រោមនេះ ជាលទ្ធផលនៃការវិភាគទឹក នៅអណ្តូងទឹកភូមិពូលុ ដែលស្ថិតនៅក្នុងតំបន់គំរោងដីសម្បទាន :

Draft

តារាង ៤.៤ : គុណភាពទឹកនៅតាមប្រព័ន្ធមួយចំនួននៅតំបន់ដីសម្បទាន

| ល.រ | ប៉ារ៉ាម៉ែត្រ | លទ្ធផល | ឯកតា | កំរិតបទដ្ឋានរបស់ ក្រសួងបរិស្ថាន |
|---|---|---|---|---|
| ១ | pH | 6.24 | - | ៦.៥-៨.៥ [១] |
| ២ | Total Coliform | 150 | Count/100ml | < ១000 [១] |
| ៣ | Magnesium(mg) | 2.00 | mg/l | - [២] |
| ៤ | Calcium(Ca) | 0.06 | mg/l | - [២] |
| ៥ | Lead(Pb) | <0.2 | mg/l | - [២] |
| ៦ | Arsenic(As) | <0.1 | mg/l | - [២] |

សំគាល់: [១] បទដ្ឋានសំរាប់គុណភាពទឹកសារធារណៈសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹករបស់ក្រសួងបរិស្ថាន
[២] មិនមានចែងនៅក្នុងបទដ្ឋានសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹករបស់ក្រសួងបរិស្ថានទេ

*ប្រភព: ក្រសួងបរិស្ថាន, ២០០៩*

### ៤.២.៤ អាកាសធាតុ

អាកាសធាតុជាស្ថានភាពរបស់បរិយាកាសនៅក្នុងតំបន់មួយ នៅពេលវេលាជាក់លាក់ណាមួយ។ អាកាសធាតុមានដូចជា សីតុណ្ហភាព កម្រិតទឹកភ្លៀង សំណើមអាកាស កម្រិតខ្យល់បក់ និងសម្ពាធបរិយាកាស។ ធាតុទាំងនេះ ត្រូវបានរៀបចំជាប្រព័ន្ធអាកាសធាតុ ដូចជា មូសុងជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ ប្រព័ន្ធអាកាសធាតុនេះ វាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រព័ន្ធនៃអេកូស៊ីស្តែមនៅក្នុងតំបន់មួយ។ ដូចនេះ ការប្រែប្រួលនូវស្ថានភាពអាកាសធាតុនៅក្នុងតំបន់ណាមួយនោះ គឺវាពិតជាកត្តាមួយដ៏ចំបងដែលមានឥទ្ធិពលទៅលើការប្រែប្រួលនៃប្រព័ន្ធអេកូស៊ីស្តែមនៅក្នុងតំបន់ណាមួយនោះយ៉ាងជាក់លាក់មែន។ ហេតុដូចនេះ ការសិក្សានូវប្រព័ន្ធអាកាសធាតុនៅក្នុងតំបន់គំរោងដីសម្បទានពិតជាមានសារៈសំខាន់ណាស់សំរាប់ការសិក្សា និងតាមដានការប្រែប្រួលនូវអេកូស៊ីឡូស៊ីនៅក្នុងតំបន់នោះ។

#### ក. សីតុណ្ហភាព

តាមប្រភពទិន្នន័យស្តីពីសីតុណ្ហភាព នៅឆ្នាំ២០០៨ នៃស្ថានីយ៍ខេត្តមណ្ឌលគីរីរបស់មន្ទីធនធានទឹក និង ឧតុនិយមខេត្តមណ្ឌលគីរី បានបង្ហាញថា :

- សីតុណ្ហភាពអប្បបរមានៅខែកុម្ភៈ មានកំរិត ១៧,៦ $^{0}$C
- សីតុណ្ហភាពមធ្យមអតិបរមាប្រចាំឆ្នាំ មានកំរិត ២៩,៩៤ $^{0}$C
- សីតុណ្ហភាពមធ្យមអប្បបរមាប្រចាំឆ្នាំ មានកំរិត ១៩,៩០ $^{0}$C



Draft

**តារាង ៤.១ : សីតុណ្ហភាពប្រចាំខែ នៅឆ្នាំ ២០០៨ ( គិតជាអង្សាសេ)**

**ចំណុចគោលដៅ ( ស្ថានីយ៍) : ខេត្តមណ្ឌលគិរី**

| ខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យម |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អប្បបរមា | ១៨.៧ | ១៧.៦ | ២០.៣ | ២១.៥ | ២១.២ | ២១ | ២០.៤ | ២០ | ១៩.៦ | ២០.១ | ១៩.៦ | ១៨.៩ | ១៩.៩ |
| អតិបរមា | ២៨.៥ | ២៩ | ៣០.៨ | ៣១.៨ | ៣០.៩ | ៣១ | ៣០.២ | ២៩.៧ | ២៩ | ៣០.៣ | ២៩.៥ | ២៨.៦ | ៣០ |

*ប្រភព: ស្ថានីយ៍ឧតុនិយម ខេត្តមណ្ឌលគិរី, ២០០៨*

### ខ. កម្រិតទឹកភ្លៀង

តាមរយៈទិន្នន័យរបស់ស្ថានីយ៍ឧតុនិយមខេត្តមណ្ឌលគិរី ស្តីពីរបបទឹកភ្លៀងធ្លាក់រយៈពេល ៣ឆ្នាំ គិតពីឆ្នាំ ២០០៦ ដល់ ២០០៨ បានបង្ហាញថា :

- របបទឹកភ្លៀងជាមធ្យមមានចំនួន ១៥៣៧.៣៣ មីលីម៉ែត្រ
- របបទឹកភ្លៀងអតិបរមា គឺនៅខែសីហា ឆ្នាំ ២០០៧ ដែលកម្រិតទឹកភ្លៀងបានកើនឡើងរហូតដល់ ៥៣៣.៦ មីលីម៉ែត្រ
- របបទឹកភ្លៀងអប្បបរមានៅខែ មករា (២០០៦, ២០០៧ និង ២០០៨) ខែកុម្ភៈ (២០០៦ និង២០០៧) និងខែធ្នូ (២០០៦ និង២០០៧) គឺមិនមាននូវភ្លៀងធ្លាក់ទេ (០ មីលី ម៉ែត្រ)

**តារាង ៤.២ : បរិមាណទឹកភ្លៀងប្រចាំខែ ចាប់តាំងពីឆ្នាំ ១៩៩៥-២០០៧ ( គិតជា ម.ម)**

**ចំណុចគោលដៅ ( ស្ថានីយ៍) : ខេត្តមណ្ឌលគិរី**

| ខែ / ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | *សរុប* |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០៦ | - | - | ៣៦.២ | ២០២.៩ | ២៦៧.៥ | ១១៩.៥ | ២៧៣.២ | ៤៤៨.៥ | ១០៧.៥ | * | * | - | ១៤៥៥.៣ |
| ២០០៧ | - | - | * | * | * | ២១៣.២ | ២៤៤ | ៥៣៣.៦ | ២៨៩.៩ | ២២៩.២ | ៦១ | - | ១៥៧០.៩ |
| ២០០៨ | - | ២២ | ៨៨.៤ | ១៦៥.២ | ២៦១.៤ | ៨៩.៥ | ១២៣.៣ | ១៩៤.៩ | ៣៨៦.៨ | ៣៨៦.៨ | ១១២.២ | ១៤២.១ | ១៥៨៩.៨ |
| សរុប | ០ | ២២ | ១២៤.៦ | ៣៦៨.១ | ៥២៨.៩ | ៤២២.២ | ៦៤០.៥ | ១១៧៧ | ៧៨៤.២ | ៦១៦ | ១៧៣.២ | ១៤២.១ | ៤៦១២ |
| មធ្យមភាគ | ០ | ២២ | ៦២.៣ | ១៨៤.០៥ | ២៦៤.៤៥ | ១៤០.៧៣ | ២១៣.៥ | ៣៩២.៣៣ | ២៦១.៤ | ៣០៨ | ៨៦.៦ | ១៤២.១ | ១៥៣៧.៣៣ |

*ប្រភព: ស្ថានីយ៍ឧតុនិយម ខេត្តមណ្ឌលគិរី, ២០០៨*

* *សំគាល់ : - គ្មានភ្លៀង*

** គ្មានទិន្នន័យ*

Draft

## ៤.៣ ធនធានជីវសាស្ត្រ

### ៤.៣.១ ធនធានព្រៃឈើ

តំបន់ដីសម្បទានទាំងមូលមាននូវប្រភេទព្រៃចំនួន ៥ រួមមាន ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃផ្សេងៗ និងដីគ្មានគំរបព្រៃ។ ទោះជាយ៉ាងណា ប្រភេទព្រៃស្រោង និងពាក់កណ្តាលស្រោង និង ផ្ទៃដីពាក់ព័ន្ធនឹងប្រជាជនត្រូវបានកាត់ចេញ និងរក្សាទុកជាសម្បត្តិរបស់រដ្ឋ។ ហេតុនេះក្រុមហ៊ុនអាចធ្វើការវិនិយោគដាំដើមកៅស៊ូ តែនៅលើដីព្រៃល្បោះ ព្រៃផ្សេងៗ ព្រៃគុម្ពោតបៃតង និងដីគ្មានគំរបព្រៃតែប៉ុណ្ណោះ។

### ៤.៣.២ ស្ថានភាពគំរបព្រៃឈើ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយសំបូរទៅដោយធនធានធម្មជាតិ ពិសេសធនធានព្រៃឈើមុនឆ្នាំ ១៩៧០ មានព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ១៣.២២៧.១០០ ហិកតា គឺស្មើនឹង ៧៣% នៃផ្ទៃដីប្រទេស។ ដោយឡែកមុនឆ្នាំ ១៩៧០ នៅក្នុងខេត្តមណ្ឌលគិរីវិញ មានព្រៃឈើគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ១.៣៦៦.៧០០ ហិកតា គឺស្មើនឹង ៩៤% នៃផ្ទៃដីខេត្ត។

**តារាង ៤.៤ : ស្ថានភាពគំរបព្រៃឈើកម្ពុជា ប្រចាំខេត្តមណ្ឌលគិរី ឆ្នាំ ២០០២**

**របស់** Forest Resources Management (FRM), in association with Indufor Oy and SGS (Societe Generale de Surveillance)

| ប្រភេទព្រៃ | ផ្ទៃដី (គិតជា ហិកតា) | ផ្ទៃដី (គិតជា ភាគរយ) |
|---|---|---|
| ព្រៃស្រោង | ១៦០.៧០៧ | ១៣.០១ |
| ព្រៃពាក់កណ្តាលស្រោង | ១៧៨.៣៧២ | ១៤.៤៤ |
| ព្រៃល្បោះ | ៨៧៣.១៣២ | ៧០.៧៣ |
| ព្រៃផ្សេងៗ | ២២.៤៨៣ | ១.៨២ |
| **សរុបផ្ទៃដីព្រៃ** | **១.២៣៤.៦៩៤** | **១០០** |

*ប្រភព : ធនធានគំរបព្រៃឈើកម្ពុជា*

ហើយចំពោះស្ថានភាពគំរបព្រៃនៅក្នុងតំបន់សិក្សាវិញ បើផ្អែកតាមផែនទីគំរបព្រៃ យើងសង្កេតឃើញមាននូវប្រភេទព្រៃដូចខាងក្រោម (ឧបសម្ព័ន្ធ : ១-៩)។

**តារាង ៤.៥ : ស្ថានភាពគំរបព្រៃឈើក្នុងតំបន់សិក្សា**

| ប្រភេទព្រៃ | ផ្ទៃដី (គិតជា ហិកតា) | ផ្ទៃដី (គិតជា ភាគរយ) |
|---|---|---|
| ព្រៃស្រោង | ៤៨៨.៥ | ១១.៤៣ |

| | | |
|---|---|---|
| ព្រៃពាក់កណ្ដាលស្រោង | ៤៣៩.២ | ១០.២៧ |
| ព្រៃល្បោះ | ២៥០៦.២ | ៥៨.៦៧ |
| ព្រៃផ្សេងៗ | ៦១៩ | ១៤.៤៨ |
| ផ្ទៃដីគ្មានគំរបព្រៃ | ២២០.១ | ៥.១៥ |
| **សរុប** | **៤២៧៣** | **១០០** |

*ប្រភព : ផែនទីគំរបព្រៃឈើឆ្នាំ ២០០៦*

### ៤.៣.៣ លទ្ធផលនៃការសិក្សាធនធានព្រៃឈើ

យោងតាមការសិក្សាស្រាវជ្រាវរបស់ **Green Environment Group Co., Ltd** ដោយរាប់នូវប្រភេទឈើដែលមាននៅក្នុងតំបន់ដីសម្បទាន ដោយមានវិធីសាស្ត្រដូចខាងក្រោមនេះ

ការសិក្សាអង្កេតព្រៃឈើគឺ : ប្រើប្រាស់វិធីសាស្ត្រសិក្សាដោយកំណត់យកទីតាំងព្រៃចំនួន ១២ សំណាក ដោយស្ថិតនៅក្នុងទីតាំងដាច់ដោយឡែកៗពីគ្នា និងទីតាំងនីមួយៗមាន ទំហំ ៥០ម x ៥០ម ត្រូវនឹងក្រឡាផ្ទៃចំនួន ២.៥០០ម$^{២}$ ហើយដើម្បីជៀសវាងការរាប់ច្រឡំ ក្រុមការងារយើងបានធ្វើការបែងចែកសំណាកអោយទៅជាឡូត៍តូចៗចំនួន ៤ ផ្សេងៗពីគ្នា ដោយក្នុងឡូត៍នីមួយៗមានទំហំ ២៥ម x ២៥ម ត្រូវនឹងក្រឡាផ្ទៃចំនួន ៦២៥ម$^{២}$ រួចចាប់ផ្ដើមធ្វើការវាស់វែងអង្កត់ផ្ចិតដោយប្រើម៉ែត្រ និងធ្វើការកត់ត្រាជាការស្រេច។

ជាលទ្ធផលបន្ទាប់ពីការសិក្សារាប់ព្រៃឈើទាំង ១២ សំណាក យើងសង្កេតឃើញថាស្ថានភាពព្រៃដែលគំរោងបានធ្វើការស្នើសុំ គឺជាប្រភេទព្រៃល្បោះលើពាក់កណ្ដាលនៃផ្ទៃដីស្នើសុំសរុបទាំងមូល ហើយប្រភេទព្រៃដែលមាននៅក្នុងតំបន់គំរោងគឺមិនសូវជាមាននូវប្រភេទឈើមានតំលៃពាណិជ្ជកម្មឡើយ រួមជាមួយរុក្ខជាតិស្រទាប់ក្រោមមួយចំនួនផងដែរ។ ជាងនេះទៅទៀតផ្ទៃមុខកាត់របស់ប្រភេទឈើទាំងនោះជាមធ្យមស្ថិតនៅក្នុងចន្លោះពី ១០ សង់ទីម៉ែត្រ ទៅ ១៩ សង់ទីម៉ែត្រ តែក៏មានមួយចំនួនតូចបំផុតមានទំហំធំ ដែលស្ថិតនៅចន្លោះពី ៤០ សង់ទីម៉ែត្រ ដល់ ៤៩ សង់ទីម៉ែត្រ។

យោងតាមការសិក្សាលើផ្ទៃដី ២៧.៥០០ម$^{២}$ នៃព្រៃទំហំ ៤២៧៣ ហិកតាក្នុងដីសម្បទាននេះមានប្រភេទឈើសរុបចំនួន ៣២ ប្រភេទ។ ក៏ដូចគ្នាផងដែរក្នុងការសិក្សានេះ យើងសង្កេតឃើញមាន :

- ឈើដែលមានអង្កត់ផ្ចិតពី ១០-១៩ស.ម រួមមាន កណ្ដោល = ១ដើម, ក្រូចព្រៃ = ៣ដើម, ក្របីបី = ២ដើម, គគីរ = ៦ដើម, ចំបក់ = ៨ដើម, ដង្ហៀបក្អាម = ២ដើម, ត្រាច = ៥ដើម, ត្រចៀកកណ្ដុរ = ៣ដើម, ត្បែង = ៩ដើម, ថ្ងាន់ = ១ដើម, បេង = ១ដើម, ពពេល = ១ដើម, ពភ្លា = ១៧ដើម,ភ្លាស្បូវ = ១ដើម, រកា = ៣ដើម, រាំងភ្នំ = ៣១ដើម, ល្បៀង = ១៩ដើម, ល្វាង = ១ដើម, ស្រម៉ = ៧ដើម, ស្វាយព្រៃ = ២ដើម, ស្រឡៅ = ២១ដើម សុក្រំ = ៤០ដើម, ស្លែង = ៦ដើម, និង ស្រទាប់ = ៨ដើម។



Draft

- ឈើដែលមានអង្កត់ផ្ចិតពី ២០-២៩ ស.ម រួមមាន កកោះ = ១ដើម, គគីរ = ៧ដើម, ផ្តៅស្រែង = ១ដើម, ដង្កៀបក្តាម = ១ដើម, ត្បែង = ៨ដើម, ផ្ចៀក = ១ដើម, ធ្នឹក = ៣ដើម, ព្រីង = ១ដើម, ពភ្លា = ១ដើម, រាំងភ្នំ = ២៥ដើម, ល្បៀង = ៣ដើម, ស្រឡៅ = ២ដើម, សុក្រំ = ១៤ដើម, ស្លែង = ១ដើម និង ស្រទាប់ = ២ដើម ។
- ឈើដែលមានអង្កត់ផ្ចិតពី ៣០-៣៩ ស.ម រួមមាន គគីរ = ២ដើម, ចំបក់ = ១ដើម, ជ្រៃ = ១ដើម, ឈ្លីក = ១ដើម, ផ្ចៀក = ២ដើម, ពពេល = ១ដើម, ព្រីង = ១ដើម, រាំងភ្នំ = ១៨ដើម, ល្បៀង = ២ដើម, ស្រឡៅ = ១ដើម, សុក្រំ = ៧ដើម និង អណ្តាតគោ = ១ដើម ។
- ឈើដែលមានអង្កត់ផ្ចិតពី ៤០-៤៩ ស.ម រួមមាន ជ្រៃ = ១ដើម, ត្បែង = ៣ដើម, ផ្ចៀក = ១ដើម, ព្រីង = ១ដើម និង រាំងភ្នំ = ៤២ដើម ។

សូមមើលបន្ថែមទាក់ទងនឹងលទ្ធផលនៃការធ្វើអង្កេតលើប្រភេទព្រៃដូចខាងក្រោម :

**តារាង ៤.៦ : ការសិក្សាអង្កេតឈើប្រភេទព្រៃក្នុងទីតាំងគំរោង SETHIKULA Co., Ltd**

| ល.រ | ឈ្មោះឈើ | ផ្ទៃមុខកាត់ឈើ (គិតជាសង់ទីម៉ែត្រ) ១២គំរូសំណាក | | | | សរុប |
|---|---|---|---|---|---|---|
| | | ១០-១៩ស.ម | ២០-២៩ស.ម | ៣០-៣៩ស.ម | ៤០-៤៩ស.ម | |
| ១ | កណ្តោល | ១ | | | | ១ |
| ២ | កកោះ | | ១ | | | ១ |
| ៣ | ក្រូចព្រៃ | ៣ | | | | ៣ |
| ៤ | ក្របី បី | ២ | | | | ២ |
| ៥ | គគីរ | ៦ | ៧ | ២ | | ១៥ |
| ៦ | ចំបក់ | ៨ | | ១ | | ៩ |
| ៧ | ផ្តៅស្រែង | | ១ | | | ១ |
| ៨ | ជ្រៃ | | | ១ | ១ | ២ |
| ៩ | ឈ្លីក | | | ១ | | ១ |
| ១០ | ដង្កៀបក្តាម | ២ | ១ | | | ៣ |
| ១១ | ត្រាច | ៥ | | | | ៥ |
| ១២ | ត្រចៀកកណ្តុរ | ៣ | | | | ៣ |
| ១៣ | ត្បែង | ៩ | ៨ | | ៣ | ២០ |
| ១៤ | ថ្នាន់ | ១ | | | | ១ |
| ១៥ | បេង | ១ | | | | ១ |
| ១៦ | ផ្ចៀក | | ១ | ២ | ១ | ៤ |
| ១៧ | ធ្នឹក | | ៣ | | | ៣ |

Draft

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | ពពេល | | ១ | ១ | | ២ |
| ១៩ | ព្រីង | | ១ | ១ | ១ | ៣ |
| ២០ | ពភ្នា | ១៧ | ១ | | | ១៨ |
| ២១ | ភ្លាស្បូវ | ១ | | | | ១ |
| ២២ | រកា | ៣ | | | | ៣ |
| ២៣ | រាំងភ្នំ | ៣១ | ២៥ | ១៨ | ៤២ | ១១៦ |
| ២៤ | ល្បៀង | ១៩ | ៣ | ២ | | ២៤ |
| ២៥ | ល្មូង | ១ | | | | ១ |
| ២៦ | ស្រមរ៉ | ៧ | | | | ៧ |
| ២៧ | [illegible] | ២ | | | | ២ |
| ២៨ | ស្រឡៅ | ២១ | ២ | ១ | | ២៤ |
| ២៩ | សុក្រំ | ៤០ | ១៤ | ៧ | | ៦១ |
| ៣០ | ស្លែង | ៦ | ១ | | | ៧ |
| ៣១ | ស្រទាប់ | ៨ | ២ | | | ១០ |
| ៣២ | អណ្តូតគោ | | | ១ | | ១ |
| **សរុប** | | **១៩៧** | **៧២** | **៣៨** | **៤៨** | **៣៩៥** |

*ប្រភព : ក្រុមសិក្សាស្រាវជ្រាវ (Green Environment Group Co., Ltd) ២០០៩*

***សំគាល់ :*** *- ព័ត៌មានលំអិតសូមមើលក្នុងឧបសម្ព័ន្ធទី៤*

*- សំណាកទី ០១ មាននិយាមកា X = 761242, Y = 1391407*
*- សំណាកទី ០២ មាននិយាមកា X = 767797, Y = 1392093*
*- សំណាកទី ០៣ មាននិយាមកា X = 768351, Y = 1392822*
*- សំណាកទី ០៤ មាននិយាមកា X = 769779, Y = 1390445*
*- សំណាកទី ០៥ មាននិយាមកា X = 770843, Y = 1388194*
*- សំណាកទី ០៦ មាននិយាមកា X = 771656, Y = 1388759*
*- សំណាកទី ០៧ មាននិយាមកា X = 771849, Y = 1387624*
*- សំណាកទី ០៨ មាននិយាមកា X = 772582, Y = 1388149*
*- សំណាកទី ០៩ មាននិយាមកា X = 771209, Y = 1386994*
*- សំណាកទី ១០ មាននិយាមកា X = 768902, Y = 1382451*
*- សំណាកទី ១១ មាននិយាមកា X = 767434, Y = 1381895*
*- សំណាកទី ១២ មាននិយាមកា X = 768046, Y = 1381308*

ទន្ទឹមនឹងនោះ ដើម្បីពិនិត្យ និងវាយតំលៃអំពីគំរបព្រៃ និងស្ថានភាពធនធានព្រៃឈើជាក់ស្តែងក្នុងពេលបច្ចុប្បន្ន។ ការថតរូបភាពពីលើអាកាសអំពីស្ថានភាពព្រៃឈើក៏ត្រូវបានធ្វើឡើងដោយប្រើប្រាស់យន្តហោះម៉ាក VH-WOC ដែលបំពាក់នូវម៉ាស៊ីនថតឌីជីថល ហើយភ្ជាប់ជាមួយប្រព័ន្ធ ជី ភី អេស (GPS) ត្រូវបានធ្វើឡើងនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ដោយអ្នកបច្ចេកទេស ជី អាយ អេស (GIS) របស់ក្រុមហ៊ុន ស៊ី ឌី អេស ខូអិលធីឌី។ វិធីសាស្ត្រនៃការថតរូបនេះ គឺថតតាមគន្លងហោះខ្សែកោង ដែលមានចំងាយសរុបប្រមាណ ១៦ គីឡូម៉ែត្រ ក្នុងរយៈកំពស់ ១២០០ ម៉ែត្រ ដោយក្រុមការងារបានថតយករូបភាពពីលើអាកាសចំនួន ១០ កន្លែង និងរូបភាព Eye View ចំនួន ៤ សន្លឹក ផងដែរ។

- យោងទៅលើរូបភាពតាម Geo-Reference (Photo Index Map-Index A) បានគ្របដណ្តប់ទៅលើផ្ទៃដីសរុប ១៤៩.៤៤ ហិកតា ដែលជាប្រភេទព្រៃល្បោះ ចំនួន ៩៨.៣១ ហិកតា។ យោងតាមផែនទី ២០០៦

Draft

ទីតាំងជាប្រភេទព្រៃល្បោះ ហើយក្រុមហ៊ុនបានដាំកៅស៊ូចំនួន ៦៤.៧៦ហិកតា នៅសល់ ៣៣.៥៥ហិកតា មិនទាន់ឈូស។

- យោងទៅលើរូបភាពតាម Geo-Reference (Photo Index Map-Index C) បានគ្របដណ្តប់ទៅលើផ្ទៃដីសរុប ១៥០.៣៧ ហិកតា ហើយរូបភាពដែលបានគ្របដណ្តប់ផ្ទៃដីគំរោង ចំនួន ១១៩.១៥ ហិកតា។ យោងតាមផែនទី ២០០៦ ទីតាំងជាប្រភេទព្រៃល្បោះ ដីគ្មានគំរបព្រៃ និងព្រៃផ្សេងៗ ហើយបើតាមរូបភាពព្រៃមានលក្ខណៈជាមធ្យម។ តាមរូបភាពបង្ហាញថា ក្រុមហ៊ុនគ្រាន់តែឈូសបែងចែកឡូតិ៍តំបន់ មិនទាន់ឈូសឆាយសំរាប់ការដាំកៅស៊ូនៅឡើយ។
- យោងទៅលើរូបភាពតាម Geo-Reference (Photo Index Map-Index E) បានគ្របដណ្តប់ទៅលើផ្ទៃដីសរុប ១៥០.៥៤ ហិកតា។ យោងតាមផែនទី ២០០៦ ទីតាំងជាប្រភេទ ដីគ្មានគំរបព្រៃ និងព្រៃផ្សេងៗ ហើយបើតាមរូបភាព ព្រៃមានលក្ខណៈជាមធ្យម ហើយក្រុមហ៊ុនមានការឈូសឆាយដាំកៅស៊ូនៅប៉ែកខាងជើងនិងខាងលិច រីឯប៉ែកខាងកើត និងខាងត្បូងឈូសឆាយផ្លូវឡូតិ៍។
- យោងទៅលើរូបភាពតាម Geo-Reference (Photo Index Map-Index G) បានគ្របដណ្តប់ទៅលើផ្ទៃដីសរុប ១៥៤.២៣ ហិកតា។ យោងតាមផែនទី ២០០៦ ទីតាំងជាប្រភេទព្រៃស្រោង និងព្រៃល្បោះ ហើយបើតាមរូបភាព ព្រៃមានលក្ខណៈជាមធ្យម ហើយក្រុមហ៊ុនមានការឈូសឆាយដាំកៅស៊ូជិតពេញរូបភាពនេះ នៅសល់ប៉ែកខាងលិច និងប៉ែកខាងជើងឈៀងខាងកើត នឹងផ្នែកខ្លះជាទីសក្ការបូជា។
- យោងទៅលើរូបភាពតាម Geo-Reference (Photo Index Map-Index J) បានគ្របដណ្តប់ទៅលើផ្ទៃដីសរុប ១៥៤.១៩ ហិកតា។ យោងតាមផែនទី ២០០៦ ទីតាំងជាប្រភេទព្រៃស្រោង ព្រៃល្បោះ និងព្រៃផ្សេងៗ ហើយបើតាមរូបភាព ព្រៃមានលក្ខណៈវិចិត្រ ហើយក្រុមហ៊ុនមានការឈូសឆាយដាំកៅស៊ូនៅប៉ែកខាងលិចនិងប៉ែកខាងត្បូង រីឯប៉ែកខាងកើត និងខាងត្បូងមិនទាន់មានការឈូសឆាយផ្លូវឡូតិ៍នៅឡើយទេ។

ដូចនេះការថតរូបពីលើអាកាសដែលបានចំនួន ១០កន្លែង គ្រប់ដណ្តប់លើផ្ទៃដីទំហំ ១.៥២៩ ហិកតា ស្មើនឹង ៣៥.៧៨% នៃទីតាំង សំរាប់ស្នើសុំដីសម្បទានសេដ្ឋកិច្ចសរុប និងរូបភាព Eye View ចំនួន ៤កន្លែង មានផ្ទៃដីទំហំ ២.០០៣ ហិកតា ដែលក្នុងនោះការថតរូបពីលើអាកាស និងរូបភាព Eye View បានបង្ហាញពីស្ថានភាពព្រៃមានលក្ខណៈមធ្យម ដោយសារប្រភេទព្រៃ លុបទៅដោយព្រៃល្បោះ។

## ៤.៣.៤ ធនធានសត្វព្រៃ

សត្វព្រៃ គឺជាជីវិតទាំងឡាយណាដែលរស់នៅក្នុងសភាពធម្មជាតិ ដោយគ្មានអន្តរាគមន៍ពីមនុស្ស ហើយមានទំនាក់ទំនងនឹងមជ្ឈដ្ឋានជុំវិញ បង្កើតបានជាប្រព័ន្ធអេកូស៊ីស្ទែម (ស្ថានប្រព័ន្ធ) *(ប្រភព : រត្ន័ ប៊ុនធឿន, ២០០៨)*។

ការសិក្សាពីធនធានសត្វព្រៃដែលមានវត្តមានក្នុង និងក្រៅតំបន់សិក្សា ត្រូវបានធ្វើឡើងតាមរយៈការសំភាសន៍ជាមួយប្រជាជន និងអាជ្ញាធរមូលដ្ឋាន (មេភូមិ ឬ មេឃុំ) ដោយប្រើប្រាស់នូវសៀវភៅមគ្គុទេសក៏នៅតំបន់វាលឆ្ពោះទៅស្គាល់ សត្វស្លាបនៃប្រទេសកម្ពុជា (រៀបរៀងដោយ : គាន់ សេដ្ឋា និង កូលីន ភូល បោះពុម្ពឆ្នាំ ២០០៣ ដោយកម្មវិធីរបស់អង្គការសមាគមន៏អភិរក្សសត្វព្រៃនៅកម្ពុជា ក្រោមកិច្ចសហប្រត្តិបត្តិការជាមួយ នាយកដ្ឋានរុក្ខា-ប្រមាញ់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) និងសៀវភៅមគ្គុទេសក៏នៅតំបន់វាលឆ្ពោះទៅស្គាល់ ថនិកសត្វនៃប្រទេសកម្ពុជា (រៀបរៀងដោយ : ម៉ែន សូរិយន់, សួន ផល្លា, ស៊ិន ប៉ូលីន និង Joe Walston បោះពុម្ពលើកទី ២ ឆ្នាំ ២០០៨ ដោយកម្មវិធីរបស់អង្គការសមាគមន៏អភិរក្សសត្វព្រៃនៅកម្ពុជា ក្រោមកិច្ចសហប្រត្តិបត្តិការជាមួយរដ្ឋបាលព្រៃឈើ) ជាជំនួយ រួមជាមួយការអង្កេតតាមរយៈដានជើង សំរែក ឬសំលេង លាមកសត្វ ចំណីអាហារដែលវាស៊ីសល់ សំបុក ឬជំរក ស្នាមខាំ ឬក្រដុសលើដើមឈើ ស្នាមក្រចកនៅលើដើមឈើ និងរុក្ខជាតិដែលសត្វព្រៃអាចស៊ីបាន ។ល។

### ក. បក្សី

ចំពោះបក្សីព្រៃ ដែលមានវត្តមាននៅក្នុងតំបន់គំរោងមានចំនួន ៥១ប្រភេទ រួមមានដូចក្នុងតារាងខាងក្រោម :

**តារាង ៤.៧ : វត្តមានបក្សីព្រៃ ក្នុងតំបន់គំរោង**

| ល.រ | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្រ្ត | PSC[1] | CITES[2] |
|---|---|---|---|---|---|
| ១ | កញ្ច្រៀចកន្ទុយត្នោត | Chestnut-tailed Starling | *Sturnus malabaricus* | p, w | |
| ២ | កេងកងតូច | Oriental Pied Hornbill | *Anthracoceros albirostris* | r | II |
| ៣ | គ្រលីងគ្រលោង | Black-collared Starling | *Sturnus nigricollis* | R | - |
| ៤ | ចកវិកកំបោយស | White-crested Laughingthrush | *Garrulax leucolophus* | R | |
| ៥ | ចាបកន្ទង់ខៀវ | Purple Sunbird | *Nectarinia asiatica* | r | |
| ៦ | ចាបកន្ទង់ចំពុះធំ | Thick-billed Flowerpecker | *Dicaeum agile* | r | |
| ៧ | ចាបកន្ទង់តូចពីងពាង | Little Spiderhunter | *Arachnothera longirostra* | r | - |
| ៨ | ចាបកន្ទង់ទ្រូងភ្លើង | Fire-breasted Flowerpecker | *Dicaeum ignipectus* | r | |
| ៩ | ចាបចៀបពោះលឿង | Orange-breasted Trogon | *Harpactes oreskios* | r | |
| ១០ | ចាបដង្កូវស្លាបពណ៌ច្រេះ | Rufescent Prinia | *Prinia rufescens* | r | |
| ១១ | ចាបដូនតាខ្នងត្នោតពោះស | Burmese Shrike | *Lanius collurioides* | r | |

| | | | | | |
|---|---|---|---|---|---|
| ១២ | ចាបដូនតាទូរស័ព្ទ | Striped Tit Babbler | *Macronous gularis* | R | |
| ១៣ | ចាបដូនតាបំពង់កប៉ោង | Puff-throated Babbler | *Pellorneum ruficeps* | r | |
| ១៤ | ចាបស៊ីរុយក្បាលប្រផេះ | Grey-headed Canary Flycatcher | *Culicicapa ceylonensis* | r | |
| ១៥ | ចាបស៊ីរុយវាលទំនាប | Tickell's Blue Flycatcher | *Cyornis ticklelliae* | r | |
| ១៦ | ចេកចៅស្លាបខ្មៅស | Common Iora | *Aegithina tiphia* | R | |
| ១៧ | ចេកទុំ | Black-naped Oriole | *Oriolus chinensis* | W, r? | - |
| ១៨ | ឆ្លងឆ្លតខៀវ | Red-billed Blue Magpie | *Urocissa erythrorhyncha* | r | |
| ១៩ | ឆ្លងឆ្លតលឿង | Rufous Treepie | *Dendrocitta vagabunda* | r | |
| ២០ | តុកកាគូ | Green-billed Malkoha | *Phaenicophaeus tristis* | R | |
| ២១ | ត្រចៀកកាំធំខ្នងត្នោត | Brown-backed Needletail | *Hirundapus giganteus* | r | |
| ២២ | ត្រចៀកកាំព្រៃ | Crested Treeswift | *Hemiprocne coronata* | r | - |
| ២៣ | ត្រសេះតូចខ្មៅ-ស | Grey-capped Pygmy Woodpecker | *Dendrocopos canicapillus* | r | - |
| ២៤ | ត្រសេះត្នោតចំពុះខ្មៅ | Rufous Woodpecker | *Celeus brachyurus* | r | |
| ២៥ | ត្រសេះធំពោះស | White-bellied Woodpecker | *Dryocopus javensis* | r | - |
| ២៦ | ត្រសេះបៃតងទ្រូងពញ្ញាក់ | Streak-throated Woodpecker | *Picus xanthopygaeus* | r | |
| ២៧ | ទទា | Chinese Francolin | *Francolinus pintadeanus* | R | |
| ២៨ | ទទាជើងបៃតង ឬ មាន់ក្រច | Scaly-breasted Partridge | *Arborophila chloropus* | r | - |
| ២៩ | ទៀវព្រៃ | Dollarbird | *Eurystomus orientalis* | r | |
| ៣០ | ទីទុយត្រីថ្ងាសត្នោត | Brown Fish Owl | *Ketupa zeylonensis* | r | II |
| ៣១ | ទីទុយធំព្រៃ | Spot-bellied Eagle Owl | *Bubo nipalensis* | r? | II |
| ៣២ | បាគូ ឬ កាពុតញើង | Common Hoopoe | *Upupa epops* | r | - |
| ៣៣ | ប៉ាក់ខៀវពោះបង្កង់ | Bar-bellied Pitta | *Pitta elliotii* | r | |
| ៣៤ | ប៉ោលតោកក្បាលព្រលែត | Lineated Barbet | *Megalaima lineate* | R | |
| ៣៥ | ប៉ោលតោកត្រចៀកបៃតង | Green-eared Barbet | *Megalaima faiostricta* | R | |
| ៣៦ | ពពិចបន្ទួលក្បាលខ្មៅ | Black-naped Monarch | *Hypothymis azurea* | R | |
| ៣៧ | ពពូលក្បាលព្រលែត | Pale-capped Pigeon | *Columba punicea* | ? | |
| ៣៨ | ពពូលចំពុះធំលឿង ឬកំប្លុក | Thick-billed Green Pigeon | *Treron curvirostra* | R | |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | ពញ្ញាក់ចង់ | Large-tailed Nightjar | *Caprimulgus macrurus* | r | |
| ៤០ | ព្រាបព្រៃ | Green Imperial Pigeon | *Ducula aenea* | r | |
| ៤១ | មាន់ព្រៃ | Red Junglefowl | *Gallus gallus* | r | - |
| ៤២ | មៀមតូចព្រៃ | Asian Barred Owlet | *Glaucidium cuculoides* | r | II |
| ៤៣ | រអាតឃ្មុំ | Oriental Honey-buzzard | *Pernis ptilorhyncus* | r | II |
| ៤៤ | លលកបាយ | Spotted Dove | *Streptopelia chinensis* | R | - |
| ៤៥ | សេកក្រិច | Vernal Hanging Parrot | *Loriculus vernalis* | r | II |
| ៤៦ | សេកសក | Red-breasted Parakeet | *Psittacula alexandri* | R | II |
| ៤៧ | សេកអាត់ | Blossom-headed Parakeet | *Psittacula roseate* | r | II |
| ៤៨ | ស្ទាំងខ្មៅសស្លាបផែក | Black Baza | *Aviceda leuphotes* | r, w? | II |
| ៤៩ | អកពស់ព្រៃ | Crested Serpent Eagle | *Spilornis cheela* | R | II |
| ៥០ | អន្ទេបកំប៉ោយខ្សែ | Spangled Drongo | *Dicrurus hottentottus* | r | |
| ៥១ | អន្ទេបទងកន្ទ្រៃ | Greater Racket-tailed Drongo | *Dicrurus paradiseus* | R | |

*ប្រភព : ការសំភាសន៍ជាមួយប្រជាជន ដោយប្រើរូបភាពរបស់សៀវភៅ គាន់ សេដ្ឋា និង កូលីន ភូល. ២០០៣*

## ខ. ថនិកសត្វ

ចំពោះពពួកថនិកសត្វ ដែលមានវត្តមាននៅក្នុងតំបន់គំរោងមានប្រមាណ ២៥ ប្រភេទ ដូចមានបង្ហាញក្នុងតារាងខាងក្រោម :

**តារាង ៤.៤ : វត្តមានថនិកសត្វក្នុង និងក្បែរតំបន់គំរោង**

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | Status[1] | CITES[2] | IUCN[3] |
|---|---|---|---|---|---|---|
| ១ | ឈ្លូស | Red Muntjac | *Muntiacus muntjak* | C | - | - |
| ២ | ជ្រូកព្រៃ | Wild Pig | *Suss scrota* | C | - | - |
| ៣ | ស្វាក្ដាម | Long-tailed Macaque | *Macaca fasscicularis* | C | II | - |
| ៤ | ស្វាត្រោស | Pig-tailed Macaque | *Macaca nemestrina* | C | II | GT |
| ៥ | ស្វាព្រាម | Silvered Langur | *Semnopithecus cristatus* | C | II | NT |
| ៦ | រញ្ជីប្រជេះ | Slow Loris | *Nycticebus coucang* | C | II | - |
| ៧ | កង្ហិច | Cambodian Striped Squirrel | *Tamiops rodolphii* | C | - | - |
| ៨ | កង្ហែន | Berdmore's Squirrel | *Menetes berdmorei* | C | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | កណ្ដុរភ្នំធំ | Large Bamboo Rat | *Rhizomys sumatrensis* | C? | - | - |
| ១០ | កន្ធីក | Northern Treeshrew | *Tupaia belangeri* | C | II | - |
| ១១ | កំប្រុកធំ | Black Giant Squirrel | *Ratufa bicolor* | C | II | - |
| ១២ | ទន្សាយគល់ | Siamese Hare | *Lepus peguensis* | C | - | - |
| ១៣ | ប្រម៉ា | East Asian Porcupine | *Hystrix brachyura* | C | - | GT |
| ១៤ | ប្រម៉ោញ | Asian Brush-tailed Porcupine | *Atherurus macrourus* | C | - | |
| ១៥ | ជ្រឹងមធ្យម | Lyle's Flying-fox | *Pteropus lylei* | C | II | - |
| ១៦ | ជ្រឹងធំ | Large Flying-fox | *Pteropus vampyrus* | - | II | - |
| ១៧ | ជ្រឹងអង្កាម | Greater Long-tongued Fruite Bat | *Macroglossus sobrinus* | C | - | - |
| ១៨ | ប្រចៀវ | Tomb Bat | *Taphozous theobaldi* | C | - | - |
| ១៩ | ខ្លាត្រី | Fishing Cat | *Prionailurus viverrinus* | C | II | NT |
| ២០ | ឆ្មាដាវ | Leopard Cat | *Prionailurus bengalensis* | C | I | |
| ២១ | ឆ្កែព្រៃ | Dhole | *Cuon alpinus* | C | II | GT |
| ២២ | ស្កាតូច | Small Asian Mongoose | *Herpestes javanicus* | C | | |
| ២៣ | សំពោចក្រអូប,សំពោចត្នោត, សំពោចដំណើប | Common Palm Civet | *Paradoxurus hermaphroditus* | C | III | |
| ២៤ | សំពោចពណិលាត | Masked Palm Civet | *Paguma larvata* | C | III | |
| ២៥ | សំពោចវល្លិ៍, ឈ្មុសវល្លិ៍ | Small Indian Civet | *Viverricula indica* | C | III | |

*ប្រភព : ការសំភាសន៍ជាមួយប្រជាជន ដោយប្រើប្រភពរបស់សៀវភៅ ម៉ែន សូរិយន់, សួន ផល្លា, ស៊ិន ប៉ូលីន និង Joe Walston . ២០០៨*

Draft

### គ. ឧរង្គសត្វ

ចំពោះពពួកឧរង្គសត្វ ដែលមានវត្តមាននៅក្នុងតំបន់គំរោង មានចំនួន ១៧ ប្រភេទ រួមមានដូចក្នុងតារាងខាងក្រោម :

**តារាង ៤.៩ : វត្តមានពពួកឧរង្គសត្វ ក្នុងតំបន់គំរោង**

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|
| ១ | ជៀស | N/A | N/A |
| ២ | ត្រកួត | N/A | N/A |
| ៣ | ថ្លែន | N/A | N/A |

| | | | |
|---|---|---|---|
| ៤ | បង្គួយ | Lizard | N/A |
| ៥ | ពញ្ញាក់ | N/A | N/A |
| ៦ | ពញ្ញាក់ក្រហម | N/A | N/A |
| ៧ | ពញ្ញាក់ខ្មៅ | N/A | N/A |
| ៨ | ពញ្ញាក់ដីរ | N/A | N/A |
| ៩ | ពស់ថ្លាន់តូច | Burmese Python | *Python molurus bivittatus* |
| ១០ | ពស់ថ្លាន់ធំ | Reticulated Python | *Python reticulates* |
| ១១ | ពស់ព្រៃ | Common Rat Snake | *Ptyas mucosus* |
| ១២ | ពស់វែក ( ក្របី) | Monocle Cobra | *Naja kaouthia* |
| ១៣ | ពស់វែក ( វនាម) | King Cobra | *Ophiophagus hannah* |
| ១៤ | ពស់វែក ( ស្រម៉ៃ) | Indochinese Spitting Cobra | *Naja siamensis* |
| ១៥ | អណ្ដើកបិទមុខស្លាកខ្មៅ | Asian Box Turtle | *Cuora amboinensis* |
| ១៦ | អណ្ដើកភ្នំ/ព្រិច/ដំបូក | Elongated Tortoise | *Indotestudo elongate* |
| ១៧ | អន្សង | Water Monitor | *Vararus salvator* |

*ប្រភព : ការសំភាសន៍ជាមួយប្រជាជន ដោយប្រើរូបភាពរបស់សៀវភៅ វត្ថី ប៊ុនធឿន. ២០០៤*

Draft

### ឃ. មច្ឆាជាតិ

ចំពោះពពួកមច្ឆាជាតិ ដែលមានវត្តមាននៅក្នុងតំបន់គំរោងមានចំនួន ២៥ ប្រភេទ រួមមានដូចក្នុងតារាងខាងក្រោម :

**តារាង ៤.១០ : វត្តមានពពួកមច្ឆាជាតិ ក្នុងតំបន់គំរោង**

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះសណ្ឋាន |
|---|---|---|---|
| ១ | ត្រីកញ្ចុះថ្ម | Asian Bumblebee | *Bagridae (Bagrid catfishes)* |
| ២ | ត្រីកន្ធប់ | Kissing Gourami | *Helostomidae* |
| ៣ | ត្រីក្រម៉ម | Hemisilurus Heterorhynchus | *Siluridae (Sheatfishes)* |
| ៤ | ត្រីត្រឱន | N/A | *Ompok hypophthalmus* |
| ៥ | ត្រីកំភ្លាញស្រែ | Treespot Gourami | *Belontiidae* |
| ៦ | ត្រីកំភ្លៀវស្ទឹង | N/A | *Siluridae (Sheatfishes)* |
| ៧ | ត្រីខ្ជឹង | Macrognathus Semiocellatus | *Mastacembelidae* |

| | | | |
|---|---|---|---|
| ៨ | ត្រីចង្វា | Barilius Nanensis | *Cyprinidae (Minnows and Carps)* |
| ១២ | ត្រីឆ្កិន | Goldfin Tinfoil Barb | *Cyprinidae (Minnows and Carps)* |
| ១៣ | ត្រីឆ្លូញ | Peacock Eel | *Macronathus siamensis* |
| ១៤ | ត្រីឆ្លាំងថ្ម | Mystus Plamiceps | *Bagridae (Bagrid catfishes)* |
| ១៥ | ត្រីផ្ទក់, ត្រីរស់ | Chevron Snakehead | *Channidae* |
| ១៥ | ត្រីផ្ទោង | N/A | *Belonidae* |
| ១៧ | ត្រីលលកស, ត្រីក្រុសភ្នំ | Poropuntius Normani | *Cyprinidae (Minnows and Carps)* |
| ១៨ | ត្រីស្រកាក្តាម/ត្រីក្រុស | Beardless Barb | *Cyprinidae (Minnows and Carps)* |
| ១៩ | ត្រីអណ្តាតឆ្កែ | Synaptura | *Achira* |
| ២០ | អន្ទង់ភ្នំ | River Eel | *Synbranchidae* |

*ប្រភព : ការសំភាសន៍ជាមួយប្រជាជន ដោយប្រើរូបភាពរបស់សៀវភៅមច្ឆាជាតិ*

**<u>បញ្ជាក់</u> : ពត៌មានពីធនធានសត្វព្រៃទាំងអស់នេះ គឺបានមកពីការសិក្សាទៅលើបណ្តាស្លាកស្នាមមួយចំនួនដូចជា : ការមើលឃើញដោយផ្ទាល់, ស្នាមជើង, សំរែក ឬសំលេង, លាមកសត្វ, ចំណីអាហារដែលវាស៊ីសល់, សំបុក ឬជំរក, ស្នាមខាំ ឬត្រដុសលើដើមឈើ, ស្នាមក្រចកនៅលើដើមឈើ, រុក្ខជាតិដែលសត្វព្រៃ អាចស៊ីបាន ។ល ។ រួមនឹងការសំភាសន៍ជាមួយនឹងប្រជាជនដែលរស់នៅក្បែរតំបន់គំរោង ដែលកត្តាទាំងអស់នេះអាចធ្វើឱ្យយើងអាចសន្និដ្ឋានបានថា ពិតជាមានទូវបណ្តាវត្តមានសត្វទាំងអស់នោះរស់នៅ ឬឆ្លងកាត់ ក្នុងតំបន់សិក្សាពិតប្រាកដមែនក្នុងកំឡុងពេល ៥ឆ្នាំចុងក្រោយនេះ ។*

**<u>សំគាល់ :</u>*

*PSC[1] = Provisonal Status in Cambodia : ស្ថានភាពបណ្តោះអាសន្ននៅក្នុងប្រទេសកម្ពុជា*

| | | | | | |
|---|---|---|---|---|---|
| *e* | : | *ផុតពូជនៅក្នុងប្រទេសកម្ពុជា* | *p* | : | *ប្រភេទផ្លាស់ប្តូរទីកន្លែងមិនសូវឆ្លងកាត់* |
| *P* | : | *ប្រភេទផ្លាស់ប្តូរទីកន្លែងឆ្លងកាត់ញឹកញាប់* | *r* | : | *មិនសូវសំបូរ* |
| *R* | : | *មានគ្រប់ទីកន្លែង* | *v* | : | *កម្រ* |
| *w* | : | *មានវត្តមាននៅវដ្តប្រាំងដោយកម្រ* | *W* | : | *មានវត្តមាននៅវដ្តប្រាំងគ្រប់ទីកន្លែង* |
| *sw* | : | *south-west ភាគនិរតី* | *se* | : | *south-east ភាគអាគ្នេយ៍* |
| *nw* | : | *north-west ភាគពាយ័ព្យ* | *ne* | : | *north-east ភាគឦសាន* |
| *?* | : | *ព័ត៌មានមិនច្បាស់លាស់* | | | |

*CITES[2] (Convention on International Trade in Endangered Species of Flora and Fauna) : គឺជាអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិ លើប្រភេទជិតផុតពូជនៃសត្វ និងរុក្ខជាតិ ។ នៅក្នុងអនុសញ្ញានេះមានចែកជាបីឧបសម្ព័ន្ធ ដើម្បីគ្រប់គ្រងការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិគឺ :*

***ឧបសម្ព័ន្ធទី I*** *: បណ្តាប្រភេទសត្វដែលទទួលការគំរាមកំហែងអាចឈានទៅរកការផុតពូជ និងផ្នែកណាមួយរបស់វា ធ្វើពាណិជ្ជកម្មទៅបាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុត ។*

Draft

*ឧបសម្ព័ន្ធទី II : បណ្តាប្រភេទសត្វដែលទទួលការគំរាមកំហែងនិងឈានទៅរកការផុតពូជ ព្រមទាំងផ្នែកណាមួយរបស់វា ធ្វើពាណិជ្ជកម្មទៅបាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុតពីភ្នាក់ងារមានសមត្ថកិច្ច ។*

*ឧបសម្ព័ន្ធទី III : បណ្តាប្រភេទសត្វ និងផ្នែកណាមួយរបស់វា ដែលត្រូវបានកំណត់អោយធ្វើពាណិជ្ជកម្ម ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ។*

*IUCN[3] (International Union for the Conservation of Nature) : សហភាពអន្តរជាតិដើម្បីអភិរក្សអន្តរជាតិ ។ ស្ថានភាពគំរាមកំហែងជាទូទៅនៅក្នុងពិភពលោករួមមាន :*

*GT : ជាប្រភេទដែលទទួលរងការគំរាមកំហែងលើពិភពលោក*

*NT : ជាប្រភេទដែលជិតទទួរងការគំរាមកំហែងលើពិភពលោក*

*DD : ជាប្រភេទដែលពុំទាន់មានទិន្នន័យគ្រប់គ្រាន់*

*STATUS[4] : ស្ថានភាពក្នុងប្រទេសកម្ពុជា (Status in Cambodia )*

*C : ជាប្រភេទដែលបានកត់ត្រាដោយអ្នកវិទ្យាសាស្ត្រ　　C? : ជាប្រភេទដែលមាននូវប្រទេសកម្ពុជា ប៉ុន្តែពុំមានការកត់ត្រានូវឡើយ*

*N/A : មិនមានទិន្នន័យ*

## ៤.៤ ធនធានសេដ្ឋកិច្ច-សង្គម

ការសិក្សាពីធនធានសេដ្ឋកិច្ច និងសង្គមរបស់ប្រជាជនដែលអាចពាក់ព័ន្ធ ឬអាចទទួលនូវឥទ្ធិលពលពីដំណើរការគំរោង ត្រូវបានធ្វើឡើងដោយផ្អែកទៅលើប្រភពទិន្នន័យរបស់ភូមិ-ឃុំ ការសម្ភាសន៏ និងការអង្កេត។ ក្នុងនោះធនធានសេដ្ឋកិច្ច និងសង្គម គឺផ្តោតសំខាន់ទៅលើភូមិ-ឃុំដែលពាក់ព័ន្ធតែប៉ុណ្ណោះ ដែលការសិក្សាគឺធ្វើឡើងដោយសង្កត់ទៅលើចំណុច ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ និងវប្បធម៌ប្រពៃណី។ ចំពោះទីតាំងដែលគំរោងស្នើសុំ មានការពាក់ព័ន្ធនឹងភូមិចំនួន៦ ដែលស្ថិតនៅក្នុងឃុំស្រែអំពូម និងឃុំប៊ូស្រាមានដូចជា ភូមិពូទឹត ភូមិពូរាំង ភូមិប៊ូស្រា ភូមិឡាំមេះ ភូមិពូចារ និងភូមិពូលុ (ឃុំប៊ូស្រា)។ ការបកស្រាយពីធនធានសេដ្ឋកិច្ច-សង្គមនេះ គឺផ្អែកជាសំខាន់លើទិន្នន័យសរុបរួម របស់ភូមិ និងចុះសិក្សាស្រាវជ្រាវផ្ទាល់។

Draft

## ៤.៤.១ ប្រជាសាស្ត្រ

### ក. ស្ថិតិប្រជាជន

ដោយយោងតាមទិន្នន័យរបស់ភូមិទាំងអស់ ដែលមានការពាក់ព័ន្ធនឹងគំរោងស្នើសុំ នាំឱ្យយើងកំណត់បានពីស្ថិតិរបស់ប្រជាជន ដែលត្រូវបានបែងចែកទៅតាមកំរិតចន្លោះអាយុនៃមនុស្សប្រុស និងមនុស្សស្រី។ នៅក្នុងនោះដែរ ចំពោះស្ថិតិមនុស្សប្រុស និងស្រី គឺត្រូវបានបែងចែកជា ៤ លំដាប់ ទៅតាមចន្លោះនៃអាយុរបស់ប្រជាជន ដែលក្នុងនោះមានដូចជា 0-៥ឆ្នាំ ៦-១៧ឆ្នាំ ១៨-៦0ឆ្នាំ និង៦១ឆ្នាំឡើងទៅ។ ខាងក្រោមនេះគឺជាស្ថិតិរបស់ប្រជាជននៅក្នុងភូមិឃុំដែលពាក់ព័ន្ធនឹងគំរោង:

**តារាង ៤.១១ : ស្ថិតិចំនួនប្រជាជន**

| ស្រុក | ឃុំ | ភូមិ | ស្ថិតិមនុស្សប្រុស និងមនុស្សស្រីតាមអាយុ (នាក់) | | | | សរុប (នាក់) | ចំនួនគ្រួសារ |
|---|---|---|---|---|---|---|---|---|
| | | | 0-៥ឆ្នាំ | ៦-១៧ឆ្នាំ | ១៨-៦0ឆ្នាំ | ៦១ឆ្នាំឡើង | | |
| ពេជ្រាដា | ប៊ូស្រា | ពូទឹត | ១២0 | ១៨៨ | ២៥២ | ១៤ | ៥៧៤ | ១៣0 |
| | | ពូរាំង | ១0១ | ១៦៨ | ២0៨ | ១៦ | ៤៩៣ | ១0១ |
| | | ប៊ូស្រា | ៧២ | ១៥0 | ២0៨ | ១៩ | ៤៤៩ | ១0៤ |
| | | ឡាំមេះ | ១0១ | ១៦0 | ២២៩ | ១១ | ៥0១ | ១១0 |
| | | ពូចារ | ៦៧ | ១៤៦ | ១៩៨ | ១៨ | ៤២៩ | ៩៣ |
| | | ពូលុ | ១១៨ | ២៩៥ | ៣៨៥ | ៣៦ | ៧៩៤ | ១៦១ |
| សរុប | | | ៥៧៩ | ១១0៧ | ១៤៤0 | ១១៤ | ៣២៤0 | ៦៩៩ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹត ពូរាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ,២00៨*

Draft

### ខ. ចំណូល និងចំណាកស្រុក

កត្តានៃចំណូល និងចំណាកស្រុករបស់ប្រជាជន គឺបង្កើតឱ្យមានបំរែបំរួលនូវស្ថិតិចំនួនគ្រួសារនៅក្នុងភូមិ និងសមាជិកគ្រួសារនីមួយៗ។ កត្តានេះបានចោទជាបញ្ហា និងនាំមកនូវផលវិបាកមួយចំនួនផងដែរដល់ការគ្រប់គ្រងស្ថិតិក្នុងភូមិសំរាប់អាជ្ញាធរមូលដ្ឋាន។ ចំពោះចំនួននៃចំណូល និងចំណាកស្រុក នឹងត្រូវធ្វើការបញ្ជាក់នៅក្នុងតារាងខាងក្រោម :

**តារាង ៤.១២ : ស្ថិតិចំណូល និងចំណាកស្រុក**

| ស្រុក | ឃុំ | ភូមិ | ចំណូលស្រុកអចិន្ត្រៃយ៍ (នាក់) | ចំណាកស្រុកអចិន្ត្រៃយ៍ (នាក់) | ស្នាក់នៅបណ្ដោះអាសន្ន (នាក់) |
|---|---|---|---|---|---|
| ពេជ្រាដា | ប៊ូស្រា | ពូទឹត | ៨ | 0 | ១ |
| | | ពូរាំង | 0 | 0 | 0 |
| | | ប៊ូស្រា | ២ | ៧ | ១៣ |

| | | | | | |
|---|---|---|---|---|---|
| | | ឡាំមេះ | ១៣ | ៤ | ០ |
| | | ពូចារ | ០ | ០ | ០ |
| | | ពូលុ | ៣ | ០ | ៦ |
| សរុប | | | ២៦ | ១១ | ២០ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹត ពូរ៉ាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ.២០០៨*

### គ. អត្រាកំណើត និងអត្រាមរណៈនៃមាតា និងទារក

យោងតាមទិន្នន័យភូមិចំនួន៧មានដូចជា ពូទឹត ពូរ៉ាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ បានសរបញ្ជាក់ឱ្យដឹងថា ស្ត្រីដែលសំរាលកូនរួចហើយគ្មានស្លាប់បាត់បង់ជីវិតក្នុងឆ្នាំ ២០០៨ គឺ១០០ភាគរយ រីឯទារកដែលបានបាត់បង់ជីវិតគឺមានចំនួនប្រមាណ ៨ភាគរយ ។

**តារាង ៤.១៣ : ស្ថិតិនៃអត្រាកំណើត និងមរណៈភាពនៃមាតា និងទារក**

| ប្រភេទ | ចំនួន (នាក់) |
|---|---|
| ស្ត្រីដែលបានសំរាលកូន | ១០៣ |
| មរណៈភាពមាតាបន្ទាប់ពីសំរាលកូន | ០ |
| ទារកដែលបានកើតរស់ | ៩៥ |
| មរណៈភាពទារកចន្លោះអាយុពី ០-១ខែ | ៨ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹត ពូរ៉ាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ.២០០៨*

## ៤.៤.២ ការអប់រំ អនក្ខរភាព និងសាលារៀន

### ក. ការអប់រំ និងអនក្ខរភាព

ការអប់រំ គឺជាកត្តាចាំបាច់មួយសំរាប់កសាងសមត្ថភាពធនធានមនុស្សនៅក្នុងសង្គម ។ សារៈសំខាន់នៃវិស័យនេះគឺជាកំលាំងចលករមួយនាំឱ្យសង្គមជាតិទទួលការរីកចំរើនឆាប់រហ័ស ។ បើពិនិត្យទៅលើទិន្នន័យភូមិចំនួន៦ ដែលត្រូវបានជ្រើសរើសយកមកសិក្សាបានឱ្យដឹងថា ចំនួនភាគរយនៃអ្នកដែលបានចូលរៀនក្នុងសាលាចំណេះទូទៅធៀបទៅនឹងអ្នកមិនចេះអក្សរមានភាពខុសគ្នាខ្លាំង គឺអ្នកបានចូលរៀនមានចំនួនទាបជាងអ្នកមិនបានរៀនសូត្រ ។ ដូច្នេះហើយទើបយើងអាចធ្វើការសន្និដ្ឋានបានថា កត្តាអនក្ខរភាពនៅតែចោទជាបញ្ហានៅឡើយ សំរាប់ប្រជាជនបែបជនបទនៅក្នុងភូមិទាំង៦ ដែលជាពិសេសនោះគឺភាពអវិជ្ជានៃមេដឹកនាំក្នុងគ្រួសារ ។

Draft

**តារាង ៤.១៩ : ស្ថិតិនៃការអប់រំ**

| ឃុំ | ភូមិ | បានរៀននៅសាលាចំណោះទូទៅចន្លោះអាយុ ៦-២៤ឆ្នាំ (ភាគរយ) | មិនចេះអក្សរចន្លោះអាយុ ១៥-៦០ឆ្នាំ (ភាគរយ) |
|---|---|---|---|
| ប៊ូស្រា | ពូទីត | ២៤ | ៧៦ |
| | ពូរាំង | ២៦ | ៧៤ |
| | ប៊ូស្រា | ២៩ | ៧១ |
| | ឡាំមេះ | ២០ | ៨០ |
| | ពូចារ | ៣២ | ៦៨ |
| | ពូលុ | ១៨ | ៨២ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទីត ពូរាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ.២០០៨*

* ***សំគាល់ :*** *ចំនួនភាគរយនេះ បានមកពីផលធៀបអ្នកចេះអក្សរ និងអ្នកមិនចេះអក្សរ ជាមួយនឹងចំនួនប្រជាជនសរុបក្នុងភូមិនីមួយៗ*

Draft

### ខ. សាលារៀន

តាមរយៈការចុះសិក្សាអង្កេតផ្ទាល់ដល់មូលដ្ឋាននៅក្នុងឃុំប៊ូស្រារបស់ស្រុកពេជ្រាដា ដែលជាឃុំមានការពាក់ព័ន្ធនឹងគំរោងវិនិយោគនេះបានឱ្យដឹងថា នៅក្នុងឃុំប៊ូស្រាមានសាលាកំរិតបឋមសិក្សាចំនួន២កន្លែង និងអនុវិទ្យាល័យចំនួន១កន្លែង។ ចំនែកឯកំរិតសិក្សាថ្នាក់វិទ្យាល័យពុំទាន់មាននៅឡើយនោះទេនៅក្នុងស្រុកពេជ្រាដាទាំងមូល។

## ៤.៤.៣ មុខរបរ និងចំណូល

### ក. មុខរបរ

ការសិក្សាពីមុខរបររបស់ប្រជាជន ដែលរស់នៅក្នុងតំបន់ជិតគំរោង អាចជាទស្សនាទានមួយ ដែលជួយក្នុងការឆ្លុះបញ្ចាំងពីស្ថានភាពមួយ នៃការរស់នៅរបស់ប្រជាជនក្នុងតំបន់។ ប្រជាជនទាំងនោះត្រូវបានចាត់ថ្នាក់ថាជា ប្រជាជនរស់នៅទីជនបទ ពីព្រោះប្រជាជនដែលរស់នៅក្នុងតំបន់នោះ មានមុខរបរភាគច្រើនជាកសិករ (ដាំដុះ រកអនុផលព្រៃឈើ និងចិញ្ចឹមសត្វ)។ បើផ្អែកលើការអង្កេត និងពិនិត្យលើទីតាំងជាក់ស្តែងលើស្ថានភាពគ្រួសារ ផ្ទៃដី និងការសម្ភាសន៍ជាមួយប្រជាជននៅតំបន់គំរោងបានឱ្យដឹងថា ប្រជាជននៅក្នុងតំបន់នោះមានមុខរបរមួយចំនួនដូចជា ធ្វើស្រែ ធ្វើចំការ ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារតិចតួច សេវាកម្ម និងរកអនុផលព្រៃឈើ។ ខាងក្រោមនេះ គឺជាតារាងស្ថិតិមុខរបរសំខាន់ៗរបស់ប្រជាជន ដែលរស់នៅតំបន់ជិតគំរោង៖

**តារាង ៤.១៥ : ស្ថិតិមុខរបរប្រជាជន**

| ស្រុក | ឃុំ | ភូមិ | មុខរបរ | | | |
|---|---|---|---|---|---|---|
| | | | ធ្វើស្រែ (គ្រួសារ) | ដំណាំចំការផ្សេងៗ (គ្រួសារ) | ចិញ្ចឹមសត្វ (គ្រួសារ) | សេវាកម្ម (គ្រួសារ) |
| ពេជ្រាដា | ប៊ូស្រា | ពូទឹត | ១២៤ | 0 | ៦៥ | ៦ |
| | | ពូរាំង | ១០១ | 0 | ៧៥ | 0 |
| | | ប៊ូស្រា | ៩១ | ៩ | ៧៦ | ៤ |
| | | ឡាំមេះ | ១១០ | 0 | ៦៤ | 0 |
| | | ពូចារ | ៧១ | ១៦ | ៩៣ | ៣ |
| | | ពូលុ | ១៦១ | 0 | ៨0 | ១៥ |
| សរុប | | | ៦៥៨ | ២៥ | ៤៥៣ | ២៨ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹត ពូរាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ, ២០០៨*

កត្តារដូវកាល គឺជាចំនុចសំខាន់មួយដែលប្រជាជនកម្ពុជាតែងតែគិតរំពៃដល់ មុននឹងប្រកបមុខរបរណាមួយ។ បញ្ហារដូវកាលគឺមានឥទ្ធិពលយ៉ាងសំខាន់មួយចំណែកផងដែរ សំរាប់ប្រជាជនដែលរស់នៅតាមទីជនបទ ជាពិសេសចំពោះអ្នកដែលប្រកបរបរកសិកម្ម។ ចំពោះប្រតិទិនរដូវកាលរបស់ប្រជាជនដែលមានការពាក់ព័ន្ធនឹងគំរោង ត្រូវបានក្រុមសិក្សាស្រាវជ្រាវ GEG ដកស្រង់លើកយកមកបង្ហាញ ដោយផ្អែកតាមការធ្វើបទសម្ភាសន៍ជាមួយប្រជាជនមូលដ្ឋាន។ មុខរបរនានារបស់ប្រជាជន នឹងមានបញ្ជាក់នៅក្នុងតារាងប្រតិទិនរដូវកាលខាងក្រោម :

**តារាង ៤.១៦ : ប្រតិទិនរដូវកាលស្តីពីមុខរបររបស់ប្រជាមូលដ្ឋាន**




*ប្រភព : ក្រុមសិក្សាស្រាវជ្រាវ (Green Environment Group Co., Ltd.), ២០០៩*

## ខ. ចំណូល

ការសិក្សាពីប្រភពប្រាក់ចំណូលរបស់ប្រជាជន គឺជាកត្តាសំខាន់មួយ ដែលអាចនាំទៅរកការប៉ាន់ស្មានពីគំរិតជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់នោះ។ ការវិភាគកំរិតប្រាក់ចំណូលនេះ គឺត្រូវបានផ្តោតសំខាន់តែទៅលើប្រាក់ចំណូលរបស់ប្រជាជន ដែលទទួលបានពីការប្រកបរបរផ្សេងៗ និងមិនវិភាគទៅលើប្រាក់ចំណូលដែលទទួលបានតាមរយៈការផ្តល់ឱ្យពីប្រភពផ្សេងឡើយ។ យោងតាមការសម្ភាសន៍ជាមួយប្រជាជនតំណាងគ្រួសារនីមួយៗនៅក្នុងភូមិ ដែលមានលំនៅស្ថានតំបន់ជិត គំរោងអាចឱ្យកំណត់បានទៅលើ ប្រាក់ចំណូលជាមធ្យមរបស់ប្រជាជននៅក្នុងគ្រួសារនីមួយៗដូចខាងក្រោមៈ

**តារាង ៤.១៧ : ចំណូលមធ្យមរបស់គ្រួសារក្នុងមួយខែ**

| ភូមិ | ចំណូលមធ្យមក្នុងមួយគ្រួសារ (រៀល) | ធ្វើស្រែ (ភាគរយ) | ដំណាំចំការផ្សេងៗ (ភាគរយ) | ចិញ្ចឹមសត្វ (ភាគរយ) | សេវាកម្ម (ភាគរយ) |
|---|---|---|---|---|---|
| ពូទីត | ១៣៧១០០ | ៦៤.១ | ០ | ៣៣ | ២.៩ |
| ពូរ៉ាំង | ៩៤១០០ | ៥៧.៤ | ០ | ៤២.៦ | ០ |
| ប៊ូស្រា | ១០៧២០០ | ៥០.៥ | ៥ | ៤២.២ | ២.៣ |
| ឡាំមេះ | ១១៨១០០ | ៦៣.២ | ០ | ៣៦.៨ | ០ |
| ពូចារ | ១៥៧៨០០ | ៣៩.៦ | ៨ | ៥០.៨ | ១.៦ |
| ពូលុ | ៩៥៧០០ | ៦២.៩ | ០ | ៣១.៣ | ៥.៨ |

*ប្រភព: ក្រុមសិក្សាស្រាវជ្រាវ (Green Environment Group Co., Ltd ). ២០០៩*

### ៤.៤.៤ ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិច ជាក្រុមនៃមនុស្សដែលរស់នៅក្នុងតំបន់ណាមួយតាំងពីយូរលង់ណាស់មកហើយ ទទួលរងនូវឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅតិចតួចបំផុត។ នៅតំបន់នៃគំរោងវិនិយោគដាំដំណាំកសិ-ឧស្សាហកម្មនេះ មានជនជាតិដើមភាគតិចពួងរស់នៅ។ ខាងក្រោមនេះ បញ្ជាក់ពីចំនួនជនជាតិដើមភាគតិច ដែលនឹងត្រូវបង្ហាញក្នុងតារាងខាងក្រោម :

**តារាង ៤.១៨ : ស្ថិតិជនជាតិដើមភាគតិចនៅតំបន់ទាក់ទ័ន្ធនឹងគំរោង**

| ឃុំ | ភូមិ | ប្រភេទជនជាតិដើមភាគតិច | ចំនួនគ្រួសារ | ចំនួនមនុស្ស(នាក់) | ចំនួនភាគរយ |
|---|---|---|---|---|---|
| ប៊ូស្រា | ពូទីត | ពួង | ១២៥ | ៥៦៦ | ៩៦ |
| | ពូរ៉ាំង | | ១០០ | ២៧១ | ៩៥ |
| | ប៊ូស្រា | | ៩២ | ៤១៥ | ៨៨ |
| | ឡាំមេះ | | ៨៨ | ៤០៥ | ៨០ |



Draft

| | | | | | |
|---|---|---|---|---|---|
| | ពូចារ | | ៨០ | ៣៨២ | ៨៦ |
| | ពូលុ | | ១៥៥ | ៧៨៩ | ៩៦ |
| សរុប | | | ៦៤០ | ២៧០៣ | |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹក ពូរ៉ាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ. ២០០៨*

** សំគាល់ : ចំនួនភាគរយនេះ បានមកពីផលធៀបរវាងចំនួនគ្រួសារជនជាតិដើមភាគតិច និងគ្រួសារសរុបនៅក្នុងភូមិនីមួយៗ*

### ៤.៤.៥ ការប្រើប្រាស់ដី និងការតាំងទីលំនៅ

ដីធ្លីគឺជាទ្រព្យសម្បត្តិដ៏ឧត្តមមួយសំរាប់ទ្រទ្រង់ដល់ការរស់នៅរបស់មនុស្ស។ ប្រជាជនដែលស្ថិតនៅតំបន់ ដែលមានការពាក់ព័ន្ធទៅនឹងគំរោងវិនិយោគនេះ បាននឹងកំពុងប្រើប្រាស់ដីធ្លីរបស់ពួកគេជាសំខាន់ទៅលើការធ្វើកសិកម្ម ក៏ដូចជាសំរាប់សាងសង់ជាលំនៅដ្ឋានផងដែរ។ ចំពោះកម្មសិទ្ធិដីធ្លីរបស់ប្រជាជននៅក្នុងស្រុកពេជ្រាដា គឺមិនទាន់មានចេញជាប្លង់កម្មសិទ្ធិដែលទទួលស្គាល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគីរីនៅឡើយទេ។ ការទទួលស្គាល់កម្មសិទ្ធិដីធ្លីត្រឹមតែកិតភូមិ-ឃុំប៉ុណ្ណោះ។ ចំនែកឯការសាងសង់គេហដ្ឋាននៅក្នុងតំបន់នោះវិញ គឺអាស្រ័យលើចំណង់ចំណូលចិត្ត និងទំលាប់របស់ពួកគាត់ ដែលផ្ទះទាំងនោះត្រូវបានបែងចែកមានដូចជា ផ្ទះប្រក់ស្បូវ ផ្ទះល្វែង និងផ្ទះប្រក់ស័ង្កសី-ហ្វីប្រូស៊ីម៉ងត៍។

**តារាង ៤.១៩ : ស្ថិតិលំនៅស្ថានប្រជាជន**

| ប្រភេទលំនៅស្ថាន | ចំនួនផ្ទះសរុបក្នុងភូមិទាំង៧ |
|---|---|
| ផ្ទះប្រក់ស្បូវ | ២៥៤ |
| ផ្ទះប្រក់ស័ង្កសិ-ហ្វីប្រូស៊ីម៉ងត៍ | ៣៧៤ |
| ផ្ទះល្វែង | ១ |
| សរុប | ៦២៩ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹក ពូរ៉ាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ. ២០០៨*

Draft

យោងតាមសៀវភៅផែនការមេរបស់គំរោង និងតាមការសំភាសន៍ជាមួយអាជ្ញាធរពាក់ព័ន្ធ និងការចុះទៅពិនិត្យទីតាំងជាក់ស្តែង បានអោយដឹងថា គំរោងរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** មានទីតាំងនៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀរ ខេត្តមណ្ឌលគិរី ដោយមានពាក់ព័ន្ធជាមួយនឹង ដីព្រៃតំណម ដីស្រែចំការប្រជាពលរដ្ឋ ដីរក្សាទុកនៅតំបន់ភ្នំ និងដីរក្សាទុកសងខាងដងអូរ ១០០-១៥០ម៉ែត្រ។ ដោយៈយោងតាមសៀវភៅផែនការមេដដែលនេះ ចំពោះដីស្រែ-ចំការប្រជាពលរដ្ឋ ដីរក្សា ចំនួន ៤៣៤ហិកតា ទុកនៅតំបន់ភ្នំ ចំនួន ៤៨៨ហិកតា និងដីរក្សាទុកសងខាងដងអូរ ១០០-១៥០ម៉ែត្រ ត្រូវបានកាត់ចេញពីតំបន់គំរោងចំនួន ៤៩១ ហិកតា (ឧបសម្ព័ន្ធ : ១-១០)។

### ៤.៤.៦ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

ការសិក្សាលើផ្លូវថ្នល់ គឺត្រូវបានលើកយកមកសិក្សានៅក្នុងឃុំប៊ូស្រាដែលស្ថិតនៅក្នុងស្រុកពេជ្រាដា។ ផ្លូវថ្នល់គឺមានសារៈសំខាន់ណាស់សំរាប់សកម្មភាពចរាចរ។ នៅក្នុងឃុំប៊ូស្រាគឺមានផ្លូវជាតិ១ខ្សែឆ្លងកាត់គឺផ្លូវជាតិលេខ៧៦ ដែលការធ្វើចរាចរលើដងផ្លូវនោះ គឺមានភាពងាយស្រួល និងជួបការពិបាកដោយអន្លើៗ ពីព្រោះផ្លូវជាតិគឺកំពុងស្ថិតនៅក្រោមការឈូសឆាយ និងសាងសង់មិនទាន់រួចរាល់នៅឡើយ។ បន្ថែមពីលើនេះទៀត ចំពោះផ្លូវលំនៅក្នុងភូមិទាំង៧ដែលត្រូវបានលើកយកមកសិក្សាវិញ គឺត្រូវបានសាងសង់រួចមួយចំនួនធំ។ ប៉ុន្តែស្ថានភាពផ្លូវទាំងអស់នោះ នឹងពិបាកធ្វើដំណើរខ្លាំងនៅពេលមានភ្លៀងធ្លាក់ ពីព្រោះដោយសារដីចាក់បំពេញថ្មីមានភាពរអិលខ្លាំង (ទិន្នន័យចុះអង្កេតខែមេសាឆ្នាំ២០០៩)។

### ៤.៤.៧ ការប្រើប្រាស់ថាមពល

តាមរយៈការធ្វើបទសម្ភាសន៍ជាមួយប្រជាជននៅក្នុងតំបន់សិក្សាបានឱ្យដឹងថា ប្រភពថាមពលដែលប្រជាជននៅទីនោះប្រើប្រាស់រួមមានដូចជា ម៉ាស៊ីនភ្លើង អាគុយ ចង្កៀងប្រេងកាត និងដុតដំរទីក។ ប្រជាជនមួយចំនួនបានប្រើប្រាស់អគ្គិសនីនៃឈ្មួញរកស៊ីឯកជន ដោយយកតម្លៃ៣៥០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង និងមួយចំនួនទៀតប្រើប្រាស់អាគុយ ដុតដំរទីក និងចង្កៀងប្រេងកាត ដែលអាស្រ័យទៅតាមលទ្ធភាពរបស់គ្រួសារនីមួយៗ។

### ៤.៤.៨ ការប្រើប្រាស់ទឹក និងអនាម័យ

តាមរយៈការចុះអង្កេត និងការធ្វើបទសម្ភាសន៍ជាមួយបណ្តាប្រជាជនដែលរស់នៅក្នុងភូមិទាំង៦ នាំឱ្យទទួលបានទិន្នន័យមួយចំនួនស្តីពីការប្រើប្រាស់ទឹករបស់ប្រជាជននៅតំបន់នោះ។ នៅក្នុងភូមិទាំងអស់នោះពុំមានសេវាកម្មផ្គត់ផ្គង់ទឹកសំរាប់ប្រើប្រាស់ដល់ប្រជាជននៅឡើយទេ។ ប្រជាជននៅក្នុងតំបន់នោះប្រើប្រាស់ប្រភពទឹកសំខាន់ជាងគេគឺ ទឹកអណ្តូងលូ អណ្តូងស្នប់ និងអណ្តូងជីកដៃ ចំនែកឯប្រភពទឹកអូរនានាដែលមាននៅជិតៗភូមិគឺគ្រាន់តែប្រើប្រាស់ជាលក្ខណៈបន្ទាប់បន្សំតែប៉ុណ្ណោះដែលមានដូចជា អូរយើល អូរប៉ុល និងអូរផែលជាដើម។

ចំពោះការទទួលទានទឹករបស់ប្រជាជននៅក្នុងតំបន់នោះត្រូវបានបែងចែកជា៣ប្រភេទគឺ ការទទួលទានទឹកដែលប្រើប្រាស់ឧបករណ៍ចំរោះ ការដាំទឹកឱ្យពុះ និងការទទួលទានទឹកមិនស្អាត។ តារាងខាងក្រោមនឹងមានបញ្ជាក់ពីអត្រានៃការទទួលទានទឹករបស់ប្រជាជនក្នុងភូមិ:

**តារាង ៤.២០ : អត្រាអនាម័យទទួលទានទឹក**

| ឃុំ | ភូមិ | ប្រភេទនៃការទទួលទានទឹក (ភាគរយ) | |
|---|---|---|---|
| | | ទឹកស្អាត | ទឹកមិនស្អាត |
| ប៊ូស្រា | ពូទីត | ១០០ | ០ |
| | ពូរាំង | ០ | ១០០ |



Draft

| | | | |
|---|---|---|---|
| | ប៊ូស្រា | ១០ | ៩០ |
| | ឡាំមេះ | ៣៦ | ៦៤ |
| | ពូចារ | ៣៧ | ៦៣ |
| | ពូលុ | ៣៧ | ៦៣ |

*ប្រភព : សៀវភៅទិន្នន័យភូមិ ពូទឹត ពូរាំង ប៊ូស្រា ឡាំមេះ ពូចារ និងពូលុ,២០០៨*

## ៤.៤.៩ សុខភាព និងការថែទាំ

សុខភាពគឺជាចំនុចសំខាន់ដែលធ្វើឱ្យសុខមាលភាពនៃជីវិត។ មណ្ឌលសុខភាព គឺជាទីកន្លែងយ៉ាងសំខាន់សំរាប់ធ្វើឱ្យសុខភាពសាធារណៈមានភាពប្រសើរឡើង។ តាមរយៈការសិក្សាអង្កេតនៅក្នុងភូមិទាំង៦បានឱ្យដឹងថា នៅក្នុងឃុំប៊ូស្រាមានមណ្ឌលសុខភាពចំនួន១កន្លែងសំរាប់បំរើសេវាកម្មព្យាបាល និងពិគ្រោះយោបល់លើសុខភាពសាធារណៈ។ ខណៈពេលដែលមានជំងឺ ប្រជាជនភូមិទាំងនោះប្រើប្រាស់ឱសថបុរាណ និងទៅព្យាបាលនៅមណ្ឌលសុខភាពក្នុងភូមិប៊ូស្រា។

នៅក្នុងនោះដែរ តាមរយៈការចុះធ្វើបទសម្ភាសន៍ជាមួយប្រជាជន និងលោកមេភូមិបានឱ្យដឹងថា នៅក្នុងភូមិទាំង៦ដែលត្រូវបានលើកយកមកសិក្សា មានប្រភេទជំងឺផ្សេងៗដែលប្រជាជននៅក្នុងតំបន់បានទទួលការយាយី និងរាតត្បាត។ ជំងឺទាំងអស់នោះរួមមានដូចជា ជំងឺគ្រុនចាញ់ គ្រុនឈាម ផ្តាសាយ គ្រុនក្តៅ រាគ របេង និងគ្រុនពោះវៀនជាដើម។

## ៤.៤.១០ ប្រពៃណី និងទំនៀមទំលាប់

ដោយការធ្វើបទសម្ភាសន៍ជាមួយប្រជាជននៅក្នុងភូមិទាំង៦ ដែលមានការពាក់ព័ន្ធនឹងគំរោងបានឱ្យដឹងថា នៅក្នុងភូមិទាំងនោះប្រជាជនប្រកាន់យកជំនឿសាសនាផ្សេងៗដូចជា ព្រហ្មណ៍សាសនាឬព្រះសែន ព្រះយេស៊ូ និងព្រះពុទ្ធ។ លើសពីនេះទៀត ប្រជាជននៅតំបន់នោះក៏មានប្រកាន់ជំនឿគោរពលើព្រៃតម និងព្រៃខ្មោចផងដែរ។

Draft